# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២១-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦១៦ ស្តីពី ការតែងតាំងឯកឧត្តម **អ៊ឹម ឈុនលឹម** ជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី ៧ (ឆ្នាំ ២០១៦ ដល់ ឆ្នាំ ២០១៩) | ៥៨០៧ |
| ២២-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦២៩ ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីជាន់ខ្ពស់ ចំនួន ០២ រូប នៃក្រសួងមហាផ្ទៃ | ៥៨០៨ |
| ២២-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៣០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប | ៥៨០៩ |
| ២៣-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៥១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ឆិន ធាបូ** (CHEN TIEBO) ជនជាតិចិន សញ្ជាតិចិន | ៥៨១០ |
| ២៣-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៥២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ កងកម្លាំងប្រដាប់អាវុធ ចំនួន ១១ រូប | ៥៨១១ |
| ២៣-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៥៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ លោក Philippe Delanghe | ៥៨១២ |
| ២៣-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៥៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះ អស់លោក និងលោកស្រី ចំនួន ០៥ រូប | ៥៨១៣ |
| ២៤-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៥៥ ស្តីពី ការផ្លាស់លោកជំទាវ **ហៃ សុន្ទរិទ្ធ** បច្ចុប្បន្ន ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋគុយបា ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម | ៥៨១៤ |
| ២៤-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៥៦ ស្តីពី ការតែងតាំងឯកឧត្តម **ហោខ សុខផល** បច្ចុប្បន្នអគ្គនាយករង នៃអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋគុយបា | ៥៨១៥ |

២៤-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៥៧ ស្តីពី ការផ្លាស់ឯកឧត្តម **ថៃ វណ្ណា** បច្ចុប្បន្ន ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហព័ន្ធរុស្ស៊ី និងជាឯកអគ្គរាជទូតតែងតាំងប្រចាំប្រទេស លីទុយអានី លេតតូនី អេសតូនី ប៉ុលហ្គារី រ៉ូមានី និងសាធារណរដ្ឋ បេឡារុស្ស ដែលមាននិវេសនដ្ឋាននៅទីក្រុងម៉ូស្គូ ចូលប្រទេសវិញ ដោយ ត្រូវចប់អាណត្តិបេសកកម្ម ៥៨១៦

## II-ក្រុមប្រឹក្សាធម្មនុញ្ញ

២៧-៦-២០១៦ -សេចក្តីសម្រេចលេខ ២២/២០១៦ កបធ.សសរ ស្តីពី ការបែងចែកក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ ៥៨១៧

២៧-៦-២០១៦ -សេចក្តីសម្រេចលេខ ២៣/២០១៦ កបធ.សសរ ស្តីពី ការចាត់តាំងអ្នកនាំពាក្យក្រុមប្រឹក្សាធម្មនុញ្ញ ៥៨១៩

## III-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

៣០-៦-២០១៦ -អនុក្រឹត្យលេខ ៧២៤ អនក្រ.តត ស្តីពី ការបញ្ចប់មុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៥៨២០

៣០-៦-២០១៦ -អនុក្រឹត្យលេខ ៧២៥ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៥៨២១

៣០-៦-២០១៦ -អនុក្រឹត្យលេខ ៧២៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៨២២

៣០-៦-២០១៦ -អនុក្រឹត្យលេខ ៧២៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៨២៣

៣០-៦-២០១៦ -អនុក្រឹត្យលេខ ៧២៨ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៥៨២៥

៣០-៦-២០១៦ -អនុក្រឹត្យលេខ ៧២៩ អនក្រ.តត ស្តីពី ការតែងតាំងទីប្រឹក្សាក្រសួងមហាផ្ទៃ ៥៨២៦

៣០-៦-២០១៦ -អនុក្រឹត្យលេខ ៧៣០ អនក្រ.តត ស្តីពី ការបញ្ចប់មុខតំណែងទីប្រឹក្សាក្រសួងមហាផ្ទៃ ៥៨២៧

៣០-៦-២០១៦ -អនុក្រឹត្យលេខ ៧៣១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៨២៨

៣០-៦-២០១៦ -អនុក្រឹត្យលេខ ៧៣២ អនក្រ.តត ស្តីពី ការលុបឈ្មោះមន្ត្រីរាជការ ៥៨២៩

### ២-សេចក្តីសម្រេច

០១-៧-២០១៦ -សេចក្តីសម្រេចលេខ ៦២ សសរ ស្តីពី ការតែងតាំងមុខងារ នាយទាហាន ៥៨៣០

### ៣-សេចក្តីណែនាំ

០៤-៧-២០១៦ -សេចក្តីណែនាំលេខ ០១ សណន ស្តីពី ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ ចតុកោណដំណាក់ កាលទី ៣ របស់រាជរដ្ឋាភិបាល ៥៨៣១

## IV~ការងារបណ្ដាក្រសួង

### ១~ ធនាគារជាតិ នៃ កម្ពុជា


១២-៥-២០១៦ -ប្រកាសលេខ ធ១៤.០១៦.១៣៥ ប្រក ស្ដីពី ការដាក់ឱ្យប្រើ វិធាន និងនីតិវិធី សភាផាត់ទាត់ជាតិ *(ត ទៅ រាជកិច្ច លេខ ៥១)* ៥៨៣៣


### ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម


១៦-៣-២០១៦ -ប្រកាសលេខ ១៩១ ឧស.កឧ.ប្រក.០៣ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន មៀង លីហេង វិនិយោគ បង្កើតរោងចក្រ ផលិតក្ដារកុងប្លាកេ និងគ្រឿងសង្ហារឹមគ្រប់ប្រភេទ ៥៩១៨

២២-៣-២០១៦ -ប្រកាសលេខ ១៩៩ ឧស.កឧ.ប្រក.០៣ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ថប ហ្វម (ខេមបូឌា) ខមភេនី លីមីធីត បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៥៩២១

២២-៣-២០១៦ -ប្រកាសលេខ ២០០ ឧស.កឧ.ប្រក.០៣ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យូ & ភែក ផេភើរ ខាថិន បង្កើតរោងចក្រ ផលិតកេសកាតុង ៥៩២៤

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦១៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **អ៊ឹម ឈុនលឹម** អធិបតីនៃកិច្ចប្រជុំពេញអង្គក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ដើម្បីជ្រើសតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញសម្រាប់អាណត្តិ៣ឆ្នាំ លើកទី៧

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម **អ៊ឹម ឈុនលឹម** ជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ៣ឆ្នាំ លើកទី៧ (ឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៩)។

**មាត្រា២** : ក្រុមប្រឹក្សាធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តតាមព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស. ១៦០៦. ៦២៣

លេខៈ ៦៧៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦*

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៤៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងមុខតំណែងមន្ត្រីជាន់ខ្ពស់ ចំនួន ០២រូប នៃក្រសួងមហាផ្ទៃ :

១- ឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ៅ ភក្តិ** អត្តលេខ ៥៤៨៦២ ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ។

២-ឯកឧត្តម **រស់ ចរុណា** ឋានន្តរសក្តិ ឧត្តមមន្ត្រីថ្នាក់លេខ១ ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១៦០៦.៦៣៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦*

លេខៈ ៦៣៣ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៣០

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈ ដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ទោ** ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- លោកឧត្តមសេនីយ៍ត្រី **ទ៊ុក ចំរើន** អត្តលេខ ៥៧៨៣៨

២- លោកឧត្តមសេនីយ៍ត្រី **ចាន់ សុខា** អត្តលេខ ២១៨៦៣ ។

**មាត្រា ២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

លេខៈ ៨៣៥ ស.ណ
សំណៅចំលងមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ពរក. ១៦០៦. ៦៣៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦*

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៥១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឆិន ធាបូ** (CHEN TIEBO) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៦៤ នៅខេត្តជាំងស៊ូ សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរ៧.១៦០៦.៦៥៨

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦*

លេខ: ៦៤៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

**គ្រឿងឥស្សរិយយស ជាតូបការ**

១- ឧត្តមសេនីយ៍ឯក ប៉ែន ប៊ុនណារី អត្តលេខ ០០០៣១៨
២- ឧត្តមសេនីយ៍ឯក កេ ជា អត្តលេខ ០០០៥៧១
៣- ឧត្តមសេនីយ៍ឯក វ៉ែន មុនី អត្តលេខ ០០៨៥៩៧
៤- ឧត្តមសេនីយ៍ឯក ស៊ឹម ស៊ុនធីម អត្តលេខ ០០១២៥៧
៥- ឧត្តមសេនីយ៍ឯក មុំ សោភ័ណ្ឌ អត្តលេខ ០០០២៦៧
៦- ឧត្តមសេនីយ៍ឯក ទឹម សន អត្តលេខ ០០០៣៦៤
៧- ឧត្តមសេនីយ៍ឯក យ៉ាល់ ពិសិដ្ឋ អត្តលេខ ០០០៣២៨
៨- ឧត្តមសេនីយ៍ឯក ឈឹម សាវុធ អត្តលេខ ០០១៩៤៨
៩- ឧត្តមសេនីយ៍ឯក ប៉ុល និត្យ អត្តលេខ ០០០៤៥៣
១០- ឧត្តមសេនីយ៍ឯក សេន ភូម៉ារី អត្តលេខ ០០៤២២៥
១១- ឧត្តមសេនីយ៍ឯក ធេព សំអាន អត្តលេខ ០០០៦៧៩

ចរស. ១៦០៦.៦៥៤

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៦៤១ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៥៣

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា**

**ចំពោះ**

លោក Philippe Delanghe

៣៧៨.១៦០៦.៦៦០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦*

លេខ: ៦៤២ ស.ណ
**សំណៅចំលងចេញតាមច្បាប់ដើម**
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

ក-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១- លោក **GAGNER Thierry**

ខ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា:**

១- លោកស្រី **សាត ធារី**
២- លោក **យ៉ា សារេត**
៣- លោក **ខូ ឌុន្នី**
៤- លោក **FAMELART JEAN LUC**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣.៧. ១៦០៦.៦៦១

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦

លេខៈ ៦៤៣ ស.ណ
សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៥៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្លាស់លោកជំទាវ **ហៃ សុន្ទារិទ្ធ** បច្ចុប្បន្ន**ឯកអគ្គរាជទូត**វិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋគុយបា ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារ. ១៦០៦.៦៦២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៦*

លេខៈ ៦៦០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៥៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **ហេង សុខផល** បច្ចុប្បន្នអគ្គនាយករង នៃអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជា**ឯកអគ្គរាជទូត**វិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋគុយបា។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]. ១៦០៦.៦៦៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៦*

លេខៈ ៦៦១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៥៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្លាស់ឯកឧត្តម **ថៃ ខណ្ណា** បច្ចុប្បន្ន**ឯកអគ្គរាជទូត**វិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហព័ន្ធរុស្ស៊ី និងជាឯកអគ្គរាជទូតតែងតាំង ប្រចាំប្រទេស លីទុយអានី លេតតូនី អេសតូនី ប៊ុលហ្គារី រ៉ូមានី និងសាធារណរដ្ឋបេឡារុស្ស ដែលមាននិវេសនដ្ឋាននៅទីក្រុងម៉ូស្គូ ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចរល. ១៦០៦.៦៦៤

លេខ: ៦៦៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៦*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**
លេខ : ៧២/២០១៦ កបធ.សសរ

# សេចក្តីសម្រេច
## ស្តីពីការបែងចែកក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ
- យោងការសម្រេចរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងអង្គពិធីផ្ទេរភារកិច្ចសមាជិក សមាជិកាក្រុមប្រឹក្សា-ធម្មនុញ្ញ នាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦
- យោងការសម្រេចរបស់កិច្ចប្រជុំពេញអង្គក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦
- តាមការចាំបាច់ចំពោះមុខរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

## សម្រេច

**ប្រការ ១.-** ត្រូវបានបែងចែកក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី៧ (២០១៦-២០១៩) ដូចខាងក្រោម :

**ក្រុមទី១**

១-សម្តេច **នរោត្តម សិរិវុឌ្ឍ**

២-ឯកឧត្តម **អ៊ុត ឈន**

៣-ឯកឧត្តម **សំ ព្រហ្មនា**

**ក្រុមទី២**

១-ឯកឧត្តម **មីន ស៊ាន**

២-ឯកឧត្តម **អ៊ឹម ឈុនលឹម**

៣-សម្តេចរាជបុត្រីព្រះរៀម **នរោត្តម បុប្ផាទេវី**

**ក្រុមទី៣**

១-លោកជំទាវ **ថែម ទេយ្យរិទ្ធ**

២-សម្តេចព្រះមហិស្សរា **នរោត្តម ចក្រពង្ស**

៣-ឯកឧត្តម **ពិត តាំងសាន**

**ប្រការ ២.-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-** សេចក្តីសម្រេចនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**អ៊ឹម ឈុនលឹម**

**ចម្លងជូន :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

-តុលាការកំពូល

-រាជកិច្ច

-សាមីខ្លួន

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ២៣/២០១៦ កបធ.សសរ

## សេចក្តីសម្រេច
## ស្តីពីការចាត់តាំងអ្នកនាំពាក្យក្រុមប្រឹក្សាធម្មនុញ្ញ

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- យោងការសម្រេចរបស់កិច្ចប្រជុំពេញអង្គក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦
- តាមការចាំបាច់ចំពោះមុខរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

## សម្រេច

**ប្រការ ១.**- ចាត់តាំងឯកឧត្តម **អ៊ុត ឈន** និងឯកឧត្តម **មីន ស៊ាន** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកនាំពាក្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី៧ (២០១៦-២០១៩)។

**ប្រការ ២.**- ឯកឧត្តម **អ៊ុត ឈន** និងឯកឧត្តម **មីន ស៊ាន** និងអគ្គលេខាធិការដ្ឋាន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យបានលទ្ធផលល្អប្រសើរ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។/

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**អ៊ឹម ឈុនលឹម**

**ចម្លងជូន :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- តុលាការកំពូល
- រាជកិច្ច
- សាមីខ្លួន
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣២៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបញ្ចប់មុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណូមពរចាំបាច់

### សម្រេច

**មាត្រា១ :** បញ្ចប់មុខតំណែង**ឧត្តមសេនីយ៍ឯក ម៉ម ស្រ៊ីមចណ្ណា** អត្តលេខ ០៦៩៥ ពីអគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ឲ្យមកបម្រើការងារនៅក្រសួងមហាផ្ទៃ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៣៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

មាត្រា ១ ._

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់សេនា ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ**វត្តឧត្តមគីរីបព្វតាសិលាគង្គា** ស្ថិតនៅក្នុងឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

១-ព្រះតេជគុណទីបធម្មោ **ឆៃ ឌុច** ព្រះចៅអធិការវត្តជ្រៃមួយរយ បច្ច័យចំនួន ១៥៣.០០០ ដុល្លារ
២-លោក **ឈីវ សៀកឡេង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៣២.៥០០ ដុល្លារ
៣-លោកស្រី **សឿន សុខណាន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៣២.៥០០ ដុល្លារ

មាត្រា ២ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ [illegible] ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦២៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ផ្តល់ជូនសប្បុរសជនចំនួន ០៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ**វត្តឧត្តមគីរីបព្វតាសិលាគង្គា** ស្ថិតនៅក្នុងឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានរាយនាមដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ក្ងយ ស៊ីខ្មៀន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ២-លោកស្រី **ហ្នួត សុភាព** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ៣-លោក **ឃឹម ឃួន** | អាចារ្យវត្ត | ថវិកាចំនួន ១១.៥០០ ដុល្លារ |
| ៤-លោក **សួង សារឿម** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ១១.៥០០ ដុល្លារ |
| ៥-លោកឧត្តមសេនីយ៍ត្រី **អ៊ុំខ ជុន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.០០០ ដុល្លារ |
| ៦-លោក **ឈិត ហាក់** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ១១.០០០ ដុល្លារ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៧២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ផ្តល់ជូនសប្បុរសជនចំនួន ២០រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ ធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ**វត្តព្រែកគង់រាជ** ស្ថិតនៅក្នុងឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល ដែលមានរាយនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ១០ គ្រឿង ផ្តល់ជូន :**

| | | |
|---|---|---|
| ១-លោក | **ហ៊ិន សុខហេង** | សប្បុរសជននៅរាជធានីភ្នំពេញ |
| ២-លោក | **សុន ទិបុល** | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៣-លោក | **ឆិត សំបូរ** | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៤-លោក | **មាស ថុល** | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៥-ឧបាសិកា | **ម៉ម ណេត** | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៦-ឧបាសក | **អ៊ុំ ចាប** | សប្បុរសជននៅខេត្តព្រៃវែង |
| ៧-ឧបាសក | **ឡាច នាង** | សប្បុរសជននៅខេត្តកណ្តាល |
| ៨-ឧបាសក | **គៀត គង់** | សប្បុរសជននៅខេត្តកណ្តាល |
| ៩-ឧបាសក | **តេង ម៉េង** | សប្បុរសជននៅខេត្តកណ្តាល |
| ១០-ឧបាសក | **សេង យាន** | សប្បុរសជននៅខេត្តកណ្តាល |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ១០ គ្រឿង ផ្តល់ជូន :**

១-ឧបាសក **ចាន់ គុំ** សប្បុរសជននៅខេត្តកណ្តាល

២-ឧបាសក **ជា សន** សប្បុរសជននៅខេត្តកណ្តាល

៣-ឧបាសក **ឆិត ថន** សប្បុរសជននៅខេត្តកណ្តាល

៤-ឧបាសក **អ៊ឹក ប៊ិច** សប្បុរសជននៅខេត្តកណ្តាល

៥-ឧបាសក **នង់ គឿន** សប្បុរសជននៅខេត្តកណ្តាល

៦-ឧបាសក **ឈុន សឿម** សប្បុរសជននៅខេត្តកណ្តាល

៧-ឧបាសក **អុម ច្រឹច** សប្បុរសជននៅខេត្តកណ្តាល

៨-ឧបាសក **ឡេង រស់** សប្បុរសជននៅខេត្តកណ្តាល

៩-ឧបាសក **អ៊ុំ សុន** សប្បុរសជននៅខេត្តកណ្តាល

១០-ឧបាសក **ចាន់ សេន** សប្បុរសជននៅខេត្តកណ្តាល

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .—**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់**ធិបឌិន្ទ** ផ្តល់ជូនសប្បុរសជនចំនួន ០៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ ធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ**វត្តព្រៃកគង់រាជ** ស្ថិតនៅក្នុងឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល ដែលមានរាយនាមដូចខាងក្រោម :

១-លោក **យាវ សុភាវុធ** អនុប្រធានការិយាល័យ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

២-លោក **ញាណ ជីលុច** អនុប្រធានការិយាល័យ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

៣-កញ្ញា **ហួន ស្រីស្រស់** មន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

៤-លោកស្រី **ថោង ធនវិន័យ** មន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

៥-លោក **ហ៊ុល សាគាំ** នាយកសាលាបឋមសិក្សាព្រែកគង់រាជ ស្រុកល្វាឯម ខេត្តកណ្តាល

៦-លោក **ចាន់ ចេង** ជំទប់ទី១ ឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល

**មាត្រា ២ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧២៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងទីប្រឹក្សាក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : តែងតាំង ទីប្រឹក្សាក្រសួងមហាផ្ទៃ ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១- លោក **សោម សុផាត** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយករង

២- លោក **គីម ឌី** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ ប្រធាននាយកដ្ឋាន។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៣០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបញ្ចប់មុខតំណែងទីប្រឹក្សាក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : បញ្ចប់មុខតំណែងលោក **ម៉ែន សំបូរ** ពីទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយករង។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ២*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៣១ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តែងតាំងមន្ត្រីរាជការចំនួន ០៣ នាក់ នៃក្រសួងអភិវឌ្ឍន៍ជនបទ ដូចមានរាយនាមខាងក្រោម ៖

១-លោកស្រី **ឡាច សាម៉ន** ជាអគ្គាធិការរងនៃអគ្គាធិការដ្ឋាន ជំនួសលោក **ជា ហៀង** ដែលបានចូលនិវត្តន៍

២-លោក **ឃី ពិសិដ្ឋ** ជាអធិការនៃអគ្គាធិការដ្ឋាន ជំនួសលោក ហេង ងួនអេង ដែលបានចូលនិវត្តន៍

៣- លោកស្រី **នន ណារ៉ែន** ជាអធិការនៃអគ្គាធិការដ្ឋានជំនួសលោកអ៊ុក ផាន់ ដែលបានចូលនិវត្តន៍

**មាត្រា ២ .-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧៣៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការលុបឈ្មោះមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា ១.-** លុបឈ្មោះ លោក **ឃុន ស្ងួនគ្រីន** ប្រធានមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព នៃក្រសួងសុខាភិបាល ចេញពីក្របខ័ណ្ឌមន្ត្រីរាជការ ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ **២០១៥** ដោយមូលហេតុសាមីខ្លួនមានធុរៈផ្ទាល់ខ្លួន និងសុខភាព។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...៧២...សសរ**

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងមុខងារ នាយទាហាន

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ  នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤  ខែ កញ្ញា  ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា  ឆ្នាំ ១៩៩៤  ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤  ខែ កញ្ញា  ឆ្នាំ ២០០០  ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨  ស្តីពីការបង្កើត អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ :** តែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូន វរសេនីយ៍ទោ **ខក យ៉ា** អត្តលេខ០៦៣៤១២ ជា ជំនួយការ រដ្ឋបាលនិងបច្ចេកទេស ការិយាល័យអនុព័ន្ធយោធាអមស្ថានទូត ព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ជំនួសវរសេនីយ៍ត្រី សាយ សក្តិសុវុទ្ធី ដែលត្រូវចប់អាណត្តិ ។

**ប្រការ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ  រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ  អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី  ០៧  ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ  ហ៊ុន  សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន**
**ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្ត**
**កម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណ**
**ដំណាក់កាលទីពេរបស់រាជរដ្ឋាភិបាល**

លេខ: ០១ [illegible]

# សេចក្តីណែនាំ

កន្លងទៅនេះក្រសួងមហាផ្ទៃបានខិតខំជំរុញការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មី ទទួលបានលទ្ធផលជាង **៨.៦លានសន្លឹក (គិតត្រឹមថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៦)** លើផែនការដែលត្រូវផ្តល់ជូន **១០.៩លាននាក់** នៅចុងឆ្នាំ ២០១៧ ហេតុនេះពិនិត្យឃើញថា ប្រជាពលរដ្ឋដែលនៅសេសសល់ មិនទាន់បានមកធ្វើអត្តសញ្ញាណប័ណ្ណនៅមាន ចំនួនច្រើននៅឡើយ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានកំណត់កាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ **ចាប់ពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦** ។

អាស្រ័យហេតុនេះ ដើម្បីជួយជំរុញនិងគាំទ្រក្រសួងមហាផ្ទៃក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរជូនប្រជាពលរដ្ឋគ្រប់អាយុបោះឆ្នោតបានប្រើប្រាស់សន្លឹកអត្តសញ្ញាណប័ណ្ណយកទៅចុះឈ្មោះ បោះឆ្នោត ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីគាំទ្រការអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការណែនាំ **ឯកឧត្តម លោកជំទាវ**ប្រធានក្រុមការងារ តាមរាជធានី ខេត្ត យកចិត្តទុកដាក់ជំរុញ ដឹកនាំ ត្រួតពិនិត្យកិច្ចការមួយចំនួនដូចខាងក្រោម៖

**១.** ជួយជំរុញការផ្សព្វផ្សាយ អប់រំ និងកៀរគរប្រជាពលរដ្ឋចូលរួមបំពេញបែបបទសុំផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឲ្យបានគ្រប់ៗគ្នា។

រាល់ការរៀបចំវេទិកាប្រមូលផ្តុំប្រជាពលរដ្ឋនានា សូមសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីត្រៀមរៀបចំក្រុមចល័តចុះបំពេញបែបបទផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ដែលមិនទាន់មាន អត្តសញ្ញាណប័ណ្ណនៅនឹងកន្លែងតែម្តង ។

**២.** ចង្អុលដឹកនាំអាជ្ញាធរឃុំ សង្កាត់រៀបចំធ្វើជំរឿនប្រជាពលរដ្ឋដែលមិនទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មី គិតទាំងអ្នកដែលមានអត្តសញ្ញាណប័ណ្ណគំរូចាស់ ហើយចងក្រងជាបញ្ជីឈ្មោះទៅតាមភូមិនីមួយៗ ។ បន្ទាប់មកត្រូវណែនាំអាជ្ញាធរក្រុង ស្រុក ខណ្ឌ រៀបចំកម្មវិធីនិងប្រតិទិនការងារដើម្បីចាត់ចែងក្រុមចល័តចុះបំពេញបែបបទផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋតាមបញ្ជីឈ្មោះដែលបានចងក្រង ដោយត្រូវផ្សព្វផ្សាយជូនដំណឹងដល់ប្រជាពលរដ្ឋឲ្យបានមុន និងត្រូវប្រមែប្រមូលទៅ

បំពេញបែបបទស្នើសុំផ្តល់អត្តសញ្ញាណប័ណ្ណគំរូថ្មីទៅតាមពេលវេលានិងទីកន្លែងដែលបានកំណត់ ។

គោលដៅចល័តផ្តល់អត្តសញ្ញាណប័ណ្ណ ត្រូវរៀបចំនៅកៀកជិតភូមិហើយចល័តពីគោលដៅមួយទៅគោលដៅមួយទៀតជាបន្តបន្ទាប់។

៣. ត្រូវណែនាំអាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋានជំរុញការធ្វើបែបបទបញ្ជូនមកអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មចំពោះករណីដែលប្រជាពលរដ្ឋបាត់អត្តសញ្ញាណប័ណ្ណ ឬខូច ឬខុសទិន្នន័យពីឯកសារសំអាង (ខុសភេទ ខុសអក្ខរាវិរុទ្ធ) ដើម្បីបោះពុម្ពជូនឡើងវិញ និងត្រូវយកចិត្តទុកដាក់ដោះស្រាយឲ្យបានឆាប់រហ័សរាល់កំហុសបច្ចេកទេសនានាដែលនាំឲ្យប្រជាពលរដ្ឋបានបំពេញបែបបទរួចហើយ តែមិនអាចទទួលសន្លឹកអត្តសញ្ញាណប័ណ្ណមកប្រើប្រាស់។

សន្លឹកអត្តសញ្ញាណប័ណ្ណដែលបានបោះពុម្ពរួចត្រូវធ្វើការបែងចែក ប្រគល់ជូនឲ្យបានឆាប់រហ័ស និងដល់ដៃប្រជាពលរដ្ឋ ។

៤. ណែនាំដល់អាជ្ញាធរក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ រៀបចំយន្តការនិងកំណត់ទីតាំងស្ថានីយ៍បំពេញបែបបទផ្តល់អត្តសញ្ញាណប័ណ្ណនៅពេលចុះឈ្មោះបោះឆ្នោត ដើម្បីដោះស្រាយបញ្ហាបន្ទាន់ដូចជាករណីប្រជាពលរដ្ឋចំណាកស្រុកត្រលប់មកស្រុកកំណើតវិញ តែមិនទាន់មានអត្តសញ្ញាណប័ណ្ណ ឬប្រជាពលរដ្ឋដែលបាត់ ឬខូច ឬអត្តសញ្ញាណប័ណ្ណមានទិន្នន័យខុសពីឯកសារសំអាង (ខុសភេទ អក្ខរាវិរុទ្ធ) ។

៥. ណែនាំ ផ្សព្វផ្សាយដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់អំពីបែបបទ នីតិវិធីពាក់ព័ន្ធនឹងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដូចជា៖

- បែបបទនីតិវិធីនៃការស្នើសុំលិខិតបញ្ជាក់ទីលំនៅក្នុងឃុំសង្កាត់ ក្នុងគោលដៅនៃការចុះឈ្មោះបោះឆ្នោត (សម្រាប់អ្នកដែលមានអាសយដ្ឋានខុសពីសន្លឹកអត្តសញ្ញាណប័ណ្ណ)
- នីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត (សម្រាប់អ្នកដែលមិនទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ) ។

ទទួលបានសេចក្តីណែនាំនេះ **ឯកឧត្តម លោកជំទាវ**ប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានតាមរាជធានីខេត្តដើម្បីគាំទ្រការអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី**
**ប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន**

**សម្តេចក្រឡាហោម ស ខេង**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៦-១៣៥ ប្រ.ក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើ
## វិធាននិងនីតិវិធី សភាផាត់ទាត់ជាតិ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី**
- បានឃើញព្រះរាជក្រមលេខ  នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ  នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងតាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦

## សម្រេច

**ប្រការ ១**.-

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់ឯកសារ "វិធាននិងនីតិវិធីសភាផាត់ទាត់ជាតិ" ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះដើម្បីជាមូលដ្ឋាននៃការអនុវត្តការផាត់ទាត់

និងទូទាត់តាមរយៈប្រព័ន្ធផាត់ទាត់ជាតិ និងប្រព័ន្ធទូទាត់រាយភ្លាមៗ ដែលបម្រើដល់កិច្ចដំណើរការ និងការគ្រប់គ្រងរបស់សភាផាត់ទាត់ជាតិនៃធនាគារជាតិនៃកម្ពុជា ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅផ្ដល់ព័ត៌មានលម្អិតអំពីប្រតិបត្តិការសភាផាត់ទាត់ជាតិ និងផ្ដល់ការណែនាំអំពីសិទ្ធិនិងកាតព្វកិច្ចរបស់សភាផាត់ទាត់ជាតិ និងសមាជិកនីមួយៗ ។ “វិធាននិងនីតិវិធីសភាផាត់ទាត់ជាតិ” នេះជាចំណងផ្លូវច្បាប់ចំពោះគ្រប់សមាជិកសភាផាត់ទាត់ជាតិ ។

**ប្រការ ៣.-**

ប្រកាសនេះអនុវត្តចំពោះគ្រប់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលផ្ដល់សកម្មភាពផាត់ទាត់ និង ទូទាត់ទាំងសមាជិកផ្ទាល់ និងមិនផ្ទាល់របស់សភាផាត់ទាត់ជាតិ ។

**ប្រការ ៤.-**

ត្រូវចាត់ទុកជានិរាករណ៍នូវ៖

- ប្រកាសលេខ ធ៩-០១៣-១២៥ ប្រ.ក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ស្ដីពីការដាក់ឲ្យប្រើវិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ
- ប្រកាសលេខ ធ៩-០១៥-០០៦ ប្រ.ក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលវិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ
- ឧបសម្ព័ន្ធនៃប្រកាសលេខ ធ៩-០១០-១៥០ ប្រ.ក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០០៨ ស្ដីពីការដាក់ឲ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន ត្រង់ចំណុចលេខគណនីរបស់អ្នកសងប្រាក់ និងអ្នកទទួលប្រាក់ ។

**ប្រការ ៥.-**

អគ្គលេខាធិការ អគ្គបេឡា អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅ

ក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា  ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៦.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦

**ទេសាភិបាល**

ជា.ចាន់តូ

**កន្លែងទទួល ៖**
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន ៖**
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា




# វិធាន និងនីតិវិធី សភាផាត់ទាត់ជាតិ

NBC NET

# NATIONAL CLEARING HOUSE RULES AND PROCEDURES




ឧបសម្ព័ន្ធប្រកាសលេខ ធ១៤.០១៦.១៣៥ ប្រ.ក
ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០១៦

# បុព្វកថា

វិធាននិងនីតិវិធីសភាផាត់ទាត់ជាតិ ត្រូវបានរៀបចំឡើងដើម្បីជាមូលដ្ឋាននៃការអនុវត្តការផាត់ទាត់និងទូទាត់  ដើម្បីបម្រើដល់កិច្ចដំណើរការនិងការគ្រប់គ្រងរបស់សភាផាត់ទាត់ជាតិ។ វិធាននិងនីតិវិធីនេះមានតួនាទីសំខាន់ណាស់សម្រាប់ការយល់ដឹងរបស់សមាជិកអំពី ដំណើរការមុខងារនិងតួនាទីរបស់សមាជិកនិងរបស់សភាផាត់ទាត់ជាតិ ។ សមាជិកសភាផាត់ទាត់ជាតិត្រូវប្រតិបត្តិ និងគោរពតាមវិធាននិងនីតិវិធីនេះ ។

ឯកសារនេះ  មានបំណងផ្តល់ព័ត៌មានលំអិតអំពីប្រតិបត្តិការសភាផាត់ទាត់ជាតិ  និងផ្តល់ការណែនាំអំពីសិទ្ធិនិងកាតព្វកិច្ចរបស់សមាជិកនីមួយៗ  ។  ដូច្នេះ  ឯកសារនេះបង្ហាញនូវតួនាទីរបស់សមាជិក  និងការគ្រប់គ្រងរបស់សភាផាត់ទាត់ជាតិ។ទន្ទឹមនោះ  ឯកសារនេះជាមូលដ្ឋាននៃកិច្ចសន្យារវាងសភាផាត់ទាត់ជាតិ និងសមាជិកនីមួយៗពាក់ព័ន្ធនឹង i)ការទទួលយក និងការអនុវត្តតាមវិធាននិងនីតិវិធីសភាផាត់ទាត់ជាតិ ii) ការតែងតាំងសភាផាត់ទាត់ជាតិជាភ្នាក់ងារទូទាត់  និង iii) កិច្ចសន្យាសេវាសភាផាត់ទាត់ជាតិ ។

វិធាននិងនីតិវិធីនេះ ជាចំណងផ្លូវច្បាប់ចំពោះគ្រប់សមាជិក ។

## មាតិកា


**១- សេចក្តីផ្តើម** ........ 1
១.១- គោលបំណង ........ 1
១.២- ច្បាប់គ្រប់គ្រង ........ 1
១.៣- កាតព្វកិច្ច ........ 1
១.៤- ការតែងតាំងសភាផាត់ទាត់ជាតិជាភ្នាក់ងារទូទាត់ ........ 2
១.៥- កិច្ចសន្យាសេវាសភាផាត់ទាត់ជាតិ ........ 3
១.៦- សេវាសភាផាត់ទាត់ជាតិ ........ 3
ក) ការដោះដូរមូលប្បទានបត្រជារូបវន្ត ........ 4
ខ) ការដោះដូរទិន្នន័យជាអេឡិចត្រូនិក ........ 4
គ) ការគ្រប់គ្រងការដោះដូរមូលប្បទានបត្រជារូបវន្តនិងទិន្នន័យជាអេឡិចត្រូនិក ........ 4
ឃ) ការដោះស្រាយបញ្ហាបច្ចេកទេស (Help Desk) ........ 4
ង) ការដោះស្រាយវិវាទ ........ 4
ច) ប្រព័ន្ធសង្គ្រោះទិន្នន័យ ........ 5
ឆ) Back-Up Bureau Services ........ 5
១.៧- រូបិយប័ណ្ណ ........ 6
ក) ការផាត់ទាត់ និងទូទាត់ជាប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិក ........ 6
ខ) ការបញ្ជូនអ៊ីនភុត/អោតភុតពាក់ព័ន្ធនឹងរូបិយប័ណ្ណ ........ 6
**២- សមាជិកភាព** ........ 7
២.១- លក្ខណៈសម្បត្តិជាសមាជិក ........ 7
២.២- ការចូលជាសមាជិក ........ 7
ក) សមាជិកផ្ទាល់ ........ 7
ខ) សមាជិកមិនផ្ទាល់ ........ 8
គ) ការប្តូរសមាជិកភាព ........ 8
២.៣- ការបញ្ឈប់ជាសមាជិកភាព ........ 8
២.៤- ការត្រៀមលក្ខណៈ និងការបំពាក់ប្រព័ន្ធសម្រាប់សមាជិក ........ 9
ក) កាតព្វកិច្ចគោរពតាមបច្ចេកទេស និងប្រតិបត្តិការ ........ 9
ខ) ការធ្វើតេស្តលើការគោរពតាមលក្ខណៈបច្ចេកទេសនិងប្រតិបត្តិការ ........ 10

គ) ការបញ្ជាក់ជូនសមាជិកនិងការត្រៀមខ្លួនដំណើរការ ........ 10
២.៥- ការចុះឈ្មោះជាសមាជិកនិងការគាំទ្ររបស់សភាផាត់ទាត់ជាតិ........ 11
ក) ការចុះឈ្មោះ ........ 11
ខ) លេខកូដសុវត្ថិភាពនិងកូនសោសម្ងាត់ (Password and E-token)........ 11
គ) ភ្នាក់ងារទូទាត់........ 11
ឃ) វិធាននិងនីតិវិធី........ 11
ង) កិច្ចសន្យាសេវាសភាផាត់ទាត់ជាតិ........ 11
ច) សេចក្តីជូនដំណឹង និងរបាយការណ៍ ........ 11
**៣- តួនាទី និងការទទួលខុសត្រូវ**........ 11
៣.១- ការគ្រប់គ្រងសភាផាត់ទាត់ជាតិ ........ 11
៣.២- គណៈកម្មាធិការប្រតិបត្តិការសភាផាត់ទាត់ជាតិ........ 12
៣.៣- ភារកិច្ចរបស់សភាផាត់ទាត់ជាតិ........ 12
៣.៤- តួនាទីរបស់ធនាគារជាតិនៃកម្ពុជា........ 13
៣.៥- ការទទួលខុសត្រូវរបស់សមាជិក ........ 13
៣.៦- ការិយាល័យគ្រប់គ្រងគណនី........ 16
៣.៧- ដែនកំណត់នៃការទទួលខុសត្រូវរបស់សភាផាត់ទាត់ជាតិ........ 16
**៤- ឧបករណ៍ទូទាត់សងប្រាក់**........ 17
៤.១- មូលប្បទានបត្រ ........ 17
៤.២- បញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក (ElectronicPayment Orders)........ 18
**៥- ប្រតិបត្តិការសភាផាត់ទាត់ជាតិ**........ 19
៥.១- ថ្ងៃធ្វើការ ........ 19
៥.២- ការស្នើសុំឈប់សម្រាករបស់សមាជិក ........ 20
៥.៣- អវត្តមានរបស់សមាជិកនៅសភាផាត់ទាត់ជាតិ ........ 20
៥.៤- អវត្តមានរបស់សមាជិកនៅមណ្ឌលដោះដូរមូលប្បទានបត្រ ........ 20
៥.៥- ម៉ោងប្រតិបត្តិការ........ 21
៥.៦- ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃអ៊ីនភុត/អោតភុត ........ 22
ក) ការផ្ទៀងផ្ទាត់អ៊ីនភុតដោយប្រព័ន្ធ Client Module ........ 22
ខ) ការផ្ទៀងផ្ទាត់ Batch ដោយប្រព័ន្ធ Client Module........ 22
គ) ការផ្ទៀងផ្ទាត់ហ្វាលដោយប្រព័ន្ធ Client Module........ 22

ឃ) ការផ្ទៀងផ្ទាត់ហ្វាលដោយសភាផាត់ទាត់ជាតិ.....23
ង) ការផ្ទៀងផ្ទាត់អោតភុតហ្វាល.....23
៥.៧- ការផាត់ទាត់ឧបករណ៍ទូទាត់សងប្រាក់.....23
៥.៨- អ៊ីនភុតមិនតាមស្តង់ដារបច្ចេកទេស.....23
៥.៩- ហ្វាល និង Batch.....24
៥.១០- ការបញ្ជូនអ៊ីនភុតហ្វាលយឺត.....24
ក). ប្រព័ន្ធផាត់ទាត់ជាតិ.....24
ខ). ប្រព័ន្ធទូទាត់រាយភ្លាមៗ.....25
៥.១១- ស្ថានភាពបន្ទាន់.....25
**៦- ការទូទាត់**.....26
៦.១- គណនីទូទាត់និងការចុះកិច្ចបញ្ជិកាទូទាត់.....26
៦.២- ការតាមដានសន្ទនីយភាព.....26
៦.៣- ការមិនអាចទូទាត់បាន.....26
១). ប្រព័ន្ធផាត់ទាត់ជាតិ.....26
២). ប្រព័ន្ធទូទាត់រាយភ្លាមៗ.....27
**៧- របាយការណ៍និងកំណត់ត្រាសាខការ**.....27
៧.១- របាយការណ៍ប្រតិបត្តិការ.....28
៧.២- របាយការណ៍សមិទ្ធផលប្រតិបត្តិការ.....28
៧.៣- របាយការណ៍ស្ថិតិ.....28
៧.៤- កំណត់ត្រាជាប្រវត្តិ (Historical Record).....29
**៨- កម្រៃ សោហ៊ុយ និងការពិន័យ**.....29
៨.១- ការបង់កម្រៃសមាជិកភាព.....29
៨.២- ការបង់កម្រៃប្រតិបត្តិការ.....30
៨.៣- ការពិន័យ.....30
ក. ចំពោះប្រព័ន្ធផាត់ទាត់ជាតិ.....30
ខ. ចំពោះប្រព័ន្ធទូទាត់រាយភ្លាមៗ.....31
**៩- ក្របខ័ណ្ឌគតយុត្តពាក់ព័ន្ធ**.....32
**ឧបសម្ព័ន្ធ១ - ពាក្យបច្ចេកទេស និងនិយមន័យ**.....33

ឧបសម្ព័ន្ធ២ - កិច្ចសន្យាស្តីពី ការទទួលយក និងការអនុវត្តតាម "វិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ" ..... 34
ឧបសម្ព័ន្ធ៣ - កិច្ចសន្យាស្តីពី ការតែងតាំងសភាផាត់ទាត់ជាតិជាភ្នាក់ងារទូទាត់ ..... 36
ឧបសម្ព័ន្ធ៤ - កិច្ចសន្យាស្តីពី សេវាសភាផាត់ទាត់ជាតិ ..... 38
ឧបសម្ព័ន្ធ៥ - ពាក្យស្នើសុំចូលជាសមាជិកសភាផាត់ទាត់ ..... 40
ឧបសម្ព័ន្ធ៦ - មូលហេតុសម្រាប់ការបង្វិលវិញនូវមូលប្បទានបត្រ ..... 41
ឧបសម្ព័ន្ធ៧ - បាត់ឧបករណ៍ទូទាត់សងប្រាក់ (Missing items) ..... 45
ឧបសម្ព័ន្ធ៨ - ស្តង់ដារឧបករណ៍ទូទាត់សងប្រាក់ ..... 47
ឧបសម្ព័ន្ធ៩ - កម្មវិធីដំណើរការប្រចាំថ្ងៃ ..... 51
ឧបសម្ព័ន្ធ១០ - កម្រៃ សោហ៊ុយ និងការពិន័យ ..... 53
ឧបសម្ព័ន្ធ១១ - របាយការណ៍ប្រតិបត្តិការប្រចាំថ្ងៃ ..... 56
ឧបសម្ព័ន្ធ១២ - ការតម្លើង និងការប្រើប្រាស់ប្រព័ន្ធ Client Module ..... 66
ឧបសម្ព័ន្ធ១៣ - បញ្ជីឈ្មោះមណ្ឌលដោះដូរមូលប្បទានបត្រ ..... 75
ឧបសម្ព័ន្ធ១៤ - ហេដ្ឋារចនាសម្ព័ន្ធ និងសុវត្ថិភាពនៃប្រព័ន្ធផាត់ទាត់ជាតិ ..... 77
ឧបសម្ព័ន្ធ១៥ - អាសយដ្ឋានសម្រាប់ទំនាក់ទំនងជាមួយសភាផាត់ទាត់ជាតិ ..... 80

## ១- សេចក្តីផ្តើម

### ១.១- គោលបំណង

វិធាននិងនីតិវិធីសភាផាត់ទាត់ជាតិគ្រប់គ្រងប្រតិបត្តិការរបស់សភាផាត់ទាត់ជាតិ និងសម្រាប់សមាជិកអនុវត្តតាមក្នុងការចេញផ្សាយទទួលយក និង/ឬ ដំណើរការមូលប្បទានបត្រ និងឧបករណ៍ទូទាត់សងប្រាក់ផ្សេងៗទៀតនៅក្នុងដំណើរការផាត់ទាត់ និងទូទាត់ឧបករណ៍ទូទាត់សងប្រាក់រួមទាំងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងឧបករណ៍ទាំងនោះ។ វិធាននិងនីតិវិធីសភាផាត់ទាត់ជាតិបម្រើដល់កិច្ចដំណើរការ និងការគ្រប់គ្រងសភាផាត់ទាត់ជាតិឱ្យប្រព្រឹត្តិទៅដោយរលូននិងជាចំណាងផ្លូវច្បាប់ចំពោះគ្រប់សមាជិកសភាផាត់ទាត់ជាតិ។

– សភាផាត់ទាត់ដែលគ្រប់គ្រងដោយធនាគារជាតិនៃកម្ពុជាហៅកាត់ថា "**សភាផាត់ទាត់ជាតិ**"
– វិធាននិងនីតិវិធីសភាផាត់ទាត់ជាតិ ហៅកាត់ថា "**វិធាននិងនីតិវិធី**"
– សមាជិកសភាផាត់ទាត់ជាតិ ហៅកាត់ថា "**សមាជិក**" ។

### ១.២- ច្បាប់គ្រប់គ្រង

វិធាននិងនីតិវិធីនេះត្រូវបានរៀបចំឡើងដោយអនុលោមតាមច្បាប់ និងប្រកាសពាក់ព័ន្ធនឹងការទូទាត់សងប្រាក់ ។

រាល់ខ្លឹមសារនៃវិធាននិងនីតិវិធីនេះ និងរាល់ការធ្វើបច្ចុប្បន្នកម្ម វិសោធនកម្ម និងការកែប្រែវិធាននិងនីតិវិធី ត្រូវអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជានិងរាល់ប្រកាសដែលបានចេញផ្សាយដោយធនាគារជាតិ ។

### ១.៣- កាតព្វកិច្ច

សមាជិកនីមួយៗមានកាតព្វកិច្ច ដូចខាងក្រោម៖

#### ក)- កិច្ចសន្យា

កិច្ចសន្យាដែលសមាជិកទាំងអស់ត្រូវចុះហត្ថលេខាជាមួយសភាផាត់ទាត់ជាតិមាន៖

- ការទទួលយក និងគោរពតាមវិធាននិងនីតិវិធីសភាផាត់ទាត់ជាតិ (ខ្លឹមសារលម្អិតមាននៅក្នុងឧបសម្ព័ន្ធ២)
- ការតែងតាំងសភាផាត់ទាត់ជាតិជាភ្នាក់ងារទូទាត់ (ខ្លឹមសារលម្អិតមាននៅក្នុងឧបសម្ព័ន្ធ៣)
- កិច្ចសន្យាសេវាសភាផាត់ទាត់ជាតិ (ខ្លឹមសារលម្អិតមាននៅក្នុងឧបសម្ព័ន្ធ៤) ។

**ខ)- ការត្រៀមខ្លួន និងការតភ្ជាប់ប្រព័ន្ធរបស់អ្នកប្រើប្រាស់**

សមាជិកទាំងអស់ត្រូវជ្រើសរើសការតភ្ជាប់ប្រព័ន្ធនិងហេដ្ឋារចនាសម្ព័ន្ធតាមតម្រូវការរបស់ខ្លួន និងត្រូវបំពេញរាល់ការងារដែលពាក់ព័ន្ធនឹងការតម្លើង និងការធ្វើតេស្តហើយបញ្ជាក់ការទទួលយកការតភ្ជាប់ដែលបានជ្រើសរើសនោះ។ ការតភ្ជាប់មានពីរជម្រើសគឺ Shared Client Module ឬ Stand-Alone Client Module។

- Shared Client Module៖ ចំពោះជម្រើសនេះ សមាជិកនីមួយៗអាចមានទីតាំងនៃការតភ្ជាប់តែមួយហើយប្រើហេដ្ឋារចនាសម្ព័ន្ធនៅសភាផាត់ទាត់ជាតិ ។

- Stand-AloneClient Module៖ ចំពោះជម្រើសនេះសមាជិកអាចមានទីតាំងនៃការតភ្ជាប់ច្រើន (សាខា) ហើយត្រូវមានហេដ្ឋារចនាសម្ព័ន្ធបន្ថែមនៅស្នាក់ការកណ្តាលរបស់ខ្លួនដើម្បីភ្ជាប់ទៅសភាផាត់ទាត់ជាតិ ។ សមាជិកដែលប្រើ Stand-Alone Client Module ចាំបាច់ត្រូវមាន Shared Client Module ជាប្រព័ន្ធបម្រុង ។

លក្ខខណ្ឌចាំបាច់នៃហេដ្ឋារចនាសម្ព័ន្ធមានចែងនៅក្នុង "ឯកសារណែនាំអ្នកប្រើប្រាស់ប្រព័ន្ធ Client Module" (Client Module User Guide) ហើយទម្រង់គំរូលិខិតសម្រាប់ការតម្លើង និងការបញ្ជាក់ការទទួលយកការតភ្ជាប់មាននៅក្នុងឧបសម្ព័ន្ធ១២ "ការតម្លើងនិងការប្រើប្រាស់ប្រព័ន្ធ Client Module" ។

សមាជិកនីមួយៗត្រូវរ៉ាប់រងចំណាយហេដ្ឋារចនាសម្ព័ន្ធបន្ថែមដែលនៅក្រៅដែនវិសាលភាព និងការទទួលខុសត្រូវរបស់សភាផាត់ទាត់ជាតិដូចជា ៖

- ហាដវែរ (Hardware) កុំព្យូទ័រសម្រាប់ភ្ជាប់ប្រព័ន្ធ Client Module របស់សភាផាត់ទាត់ជាតិ
- ការភ្ជាប់អ៊ីនធឺណែតជាមួយគេហទំព័រសភាផាត់ទាត់ជាតិ ។

**១.៤- ការតែងតាំងសភាផាត់ទាត់ជាតិជាភ្នាក់ងារទូទាត់**

ការតែងតាំងសភាផាត់ទាត់ជាតិជាភ្នាក់ងារទូទាត់ ជាកិច្ចសន្យាមួយរវាងសភាផាត់ទាត់ជាតិ និងសមាជិកនានា។ សមាជិកនីមួយៗបានផ្តល់សិទ្ធិឱ្យសភាផាត់ទាត់ជាតិធ្វើជាភ្នាក់ងាររបស់ខ្លួនក្នុងការរៀបចំនិងទទួលអ៊ីនភុតហ្វាលបញ្ជូនអោតភុតហ្វាលទៅសមាជិក និងបញ្ជូនព័ត៌មានអំពីកាតព្វកិច្ចទូទាត់សុទ្ធជាពហុភាគីរបស់សមាជិកនីមួយៗទៅការិយាល័យគ្រប់គ្រងគណនីធនាគារជាតិហៅកាត់ថា "ការិយាល័យគ្រប់គ្រងគណនី" ដើម្បីចុះកិច្ចបញ្ជិកាទូទាត់ដោយស្វ័យប្រវត្តិ។ ការតែងតាំងនិងការផ្តល់សិទ្ធិជាភ្នាក់ងារនេះ ជាកាតព្វកិច្ចរបស់សមាជិកទាំងអស់ដែលត្រូវអនុវត្តដោយការចុះកិច្ចសន្យាដោយឡែកស្តីពី "ការតែងតាំងសភាផាត់ទាត់ជាតិជាភ្នាក់ងារទូទាត់" រវាងសភាផាត់ទាត់ជាតិនិងសមាជិក

នីមួយៗ។ កិច្ចសន្យានេះមាននៅក្នុងឧបសម្ព័ន្ធ៣ "កិច្ចសន្យាស្តីពីការតែងតាំងសភាផាត់ទាត់ជាតិជាភ្នាក់ងារទូទាត់"។

**១.៥- កិច្ចសន្យាសេវាសភាផាត់ទាត់ជាតិ**

កិច្ចសន្យាសេវារវាងសភាផាត់ទាត់ជាតិនិងសមាជិក កំណត់កម្រិតគោលដែលត្រូវសម្រេចនិងជាក្របខ័ណ្ឌសម្រាប់វាស់វែងការអនុវត្តដែលជាឧបករណ៍គ្រប់គ្រងប្រសិទ្ធភាពនៃប្រព័ន្ធ។ កិច្ចសន្យានេះមាននៅក្នុងឧបសម្ព័ន្ធ៤ "កិច្ចសន្យាស្តីពីសេវាសភាផាត់ទាត់ជាតិ" ។

**១.៦- សេវាសភាផាត់ទាត់ជាតិ**

សភាផាត់ទាត់ជាតិរួមមានប្រព័ន្ធផាត់ទាត់ជាតិ (National Clearing System) និងប្រព័ន្ធទូទាត់រាយភ្លាមៗ (FAST System) ។ សភាផាត់ទាត់ជាតិ ផ្តល់សេវាផាត់ទាត់និងទូទាត់ដល់សមាជិកនិងផ្តល់ព័ត៌មានអំពីកាតព្វកិច្ចទូទាត់សុទ្ធទៅការិយាល័យគ្រប់គ្រងគណនី ។ សភាផាត់ទាត់ជាតិក៏ជាទីតាំងសម្រាប់ដោះដូរ បង្ហាញ និងទូទាត់ឧបករណ៍ទូទាត់សងប្រាក់មិនមែនសាច់ប្រាក់ (មូលប្បទានបត្រ រូបិយាណត្តិ ការផ្ទេរឥណទាន និងបញ្ជាទូទាត់សងប្រាក់ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ។ល។) ដែលបានចេញផ្សាយ និងត្រូវទូទាត់សងទៅឲ្យធនាគារសមាជិកតាមតម្លៃចារឹក និងជាកន្លែងរក្សាកំណត់ត្រាអេឡិចត្រូនិកនៃការទូទាត់ឧបករណ៍ទាំងនេះ។ ឥណទេយ្យសុទ្ធពហុភាគីអន្តរធនាគារត្រូវបានទូទាត់តាមរយៈគណនីទូទាត់របស់សមាជិកជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក ។

សភាផាត់ទាត់ជាតិ ផ្តល់សេវាផាត់ទាត់អន្តរធនាគារសម្រាប់គ្រប់ប្រភេទនៃសារ និងឧបករណ៍ទូទាត់សងប្រាក់អន្តរធនាគារ (មូលប្បទានបត្រ មូលប្បទានបត្របង្វិលវិញ ការផ្ទេរឥណទាន ឥណទានផ្ទាល់ ឥណពន្ធផ្ទាល់ដោយបង្ខំ និងឥណពន្ធផ្ទាល់ដោយសំណើ) ។ ការដោះដូរមូលប្បទានបត្រ និងមូលប្បទានបត្របង្វិលវិញជារូបវន្ត ត្រូវធ្វើឡើងនៅសភាផាត់ទាត់ជាតិ ឬនៅមណ្ឌលដោះដូរមូលប្បទានបត្រសាខាធនាគារជាតិ ហៅកាត់ថា "មណ្ឌលដោះដូរមូលប្បទានបត្រ" ដែលជាទីតាំងសុវត្ថិភាពសម្រាប់ការដោះដូរ និងផ្តល់របាយការណ៍សម្រាប់ការផ្ទៀងផ្ទាត់ឧបករណ៍ទាំងនេះ។

ដំណើរការផាត់ទាត់ ត្រូវធ្វើឡើងដោយផ្អែកលើអេឡិចត្រូនិកអ៊ីនភុតដែលបានទទួលពីសមាជិកអ៊ីនភុត និងអេឡិចត្រូនិកអោតភុតរបស់សភាផាត់ទាត់ជាតិ ។ រាល់អ៊ីនភុតចូលនិងអោតភុតចេញពីសភាផាត់ទាត់ជាតិ ត្រូវមានទម្រង់ជាអេឡិចត្រូនិក ហើយការទូទាត់សងប្រាក់ត្រូវធ្វើជា Batch ។

**ក) ការដោះដូរមូលប្បទានបត្រជារូបវន្ត**

ធនាគារជាតិ ផ្តល់ទីតាំងដែលមានសុវត្ថិភាពនៅសភាផាត់ទាត់ជាតិ និងនៅមណ្ឌលដោះដូរមូលប្បទានបត្រសម្រាប់ការដោះដូរមូលប្បទានបត្រ និងឯកសាររូបវន្តផ្សេងៗទៀត។ បញ្ជីឈ្មោះមណ្ឌលដោះដូរមូលប្បទានបត្រដែលមានបច្ចុប្បន្ននេះ មាននៅក្នុងឧបសម្ព័ន្ធ១៣ "បញ្ជីឈ្មោះមណ្ឌលដោះដូរមូលប្បទានបត្រ"។

**ខ) ការដោះដូរទិន្នន័យជាអេឡិចត្រូនិក**

ការដោះដូរទិន្នន័យ និងឯកសារផ្សេងៗទៀតជាអេឡិចត្រូនិករួមទាំងការផាត់ទាត់និងទូទាត់ឧបករណ៍ទូទាត់សងប្រាក់ទាំងអស់នឹងធ្វើឡើងជាលក្ខណៈមជ្ឈការ និងប្រព្រឹត្តិទៅនៅសភាផាត់ទាត់ជាតិដែលមានទីតាំងនៅស្នាក់ការកណ្តាលធនាគារជាតិ ។

**គ) ការគ្រប់គ្រងការដោះដូរមូលប្បទានបត្រជារូបវន្តនិងទិន្នន័យជាអេឡិចត្រូនិក**

ធនាគារជាតិ តែងតាំងអ្នកដឹកនាំការផាត់ទាត់នៅសភាផាត់ទាត់ជាតិ ដែលមានភារៈទទួលខុសត្រូវលើប្រតិបត្តិការប្រចាំថ្ងៃរួមមាន ការដោះដូរមូលប្បទានបត្រជារូបវន្ត និងសារទូទាត់-សងប្រាក់អេឡិចត្រូនិកជាលក្ខណៈមជ្ឈការនៅសភាផាត់ទាត់ជាតិ។ ទន្ទឹមនោះ ធនាគារជាតិ តែងតាំងអ្នកដឹកនាំមណ្ឌលដោះដូរមូលប្បទានបត្រនៅតាមមណ្ឌលនីមួយៗ ដែលមានភារៈដឹកនាំដំណើរការដោះដូរ មូលប្បទានបត្រជារូបវន្តរវាងសមាជិក ។

**ឃ) ការដោះស្រាយបញ្ហាបច្ចេកទេស (Help Desk)**

សភាផាត់ទាត់ជាតិ ផ្តល់សេវាក្នុងការដោះស្រាយបញ្ហាបច្ចេកទេសផ្សេងៗដល់សមាជិកដើម្បីដោះស្រាយបញ្ហាប្រព័ន្ធ ប្រតិបត្តិការ និងឆ្លើយតបនឹងចម្ងល់ផ្សេងៗពាក់ព័ន្ធគោលនយោបាយជាដើម ។ ចំពោះរាល់បញ្ហាដែលកើតឡើងសមាជិកអាចចុះចូលក្នុងប្រព័ន្ធ Help Desk ឬតាមរយៈទូរស័ព្ទលេខ ០២៣ ៧២២ ១៦៦ / ០២៣ ៧២៤ ៨៦៦ មកសភាផាត់ទាត់ជាតិ។

**ង) ការដោះស្រាយវិវាទ**

រាល់វិវាទពាក់ព័ន្ធ ត្រូវដាក់ជូនទៅប្រធានសភាផាត់ទាត់ជាតិដែលតែងតាំងដោយធនាគារជាតិដើម្បីដោះស្រាយ ។ ប្រធានត្រូវធ្វើសេចក្តីសម្រេចដោយឈរលើប្រយោជន៍រួមនៃភាគីទាំងអស់ ហើយបន្ទាប់ពីបានពិភាក្សាល្អិតល្អន់ជាមួយភាគីពាក់ព័ន្ធ សេចក្តីសម្រេចរបស់ប្រធានត្រូវចាត់ទុកជាការសម្រេចចុងក្រោយ ។ ក្នុងករណីភាគីពាក់ព័ន្ធមិនទទួលយកដំណោះស្រាយរបស់ប្រធាន ការដោះស្រាយវិវាទត្រូវធ្វើឡើងដោយផ្ទាល់រវាងភាគីនោះ ។

ក្នុងករណីមានកំហុសឆ្គងដោយមូលហេតុ សមាជិកបញ្ជូនបានបញ្ចូលនិងបញ្ជូនព័ត៌មានអំពី ការផ្ទេរឥណទានរបស់អ្នកទទួលផលមកសភាផាត់ទាត់ជាតិខុសនោះ ជាបន្ទុករបស់សមាជិកបញ្ជូន។ សមាជិកបញ្ជូននិងសមាជិកទទួល ត្រូវសហការដោះស្រាយបញ្ហាដែលកើតឡើង និងត្រូវរាយការណ៍ជាលាយលក្ខអក្សរអំពីបញ្ហា និងដំណោះស្រាយមកសភាផាត់ទាត់ជាតិ ដើម្បីទប់ស្កាត់នូវការខាតបង់ប្រយោជន៍រួមគ្នា។

**ច) ប្រព័ន្ធសង្គ្រោះទិន្នន័យ**

សភាផាត់ទាត់ជាតិ ផ្តល់ប្រព័ន្ធសង្គ្រោះទិន្នន័យពេញលេញ ដែលបានបំពាក់នៅស្នាក់ការកណ្តាលនៃធនាគារជាតិ និងនៅមណ្ឌលសង្គ្រោះរបស់ខ្លួន។ ប្រព័ន្ធសង្គ្រោះទិន្នន័យនៅស្នាក់ការកណ្តាលមានសមត្ថភាពបច្ចេកទេសផ្ទាល់ខ្លួន អាចធននឹងគ្រោះមហន្តរាយជាអតិបរមាដែលអាចធានាការស្រោចស្រង់ទិន្នន័យបានភ្លាមៗដោយស្វ័យប្រវត្តិក្នុងនោះរួមមាន ការចម្លងមកវិញនូវឃ្លាំងទិន្នន័យ (Database Replication) បណ្តាញទូរគមនាគមន៍បម្រុងហាដវែរស្ទួន (Hardware Redundancy) និងកំណត់ត្រាព័ត៌មានសម្រាប់ធ្វើសវនកម្មលើប្រតិបត្តិការទាំងអស់។

មណ្ឌលសង្គ្រោះទិន្នន័យមានពីរកន្លែង នៅសាខាធនាគារជាតិក្រុងភ្នំពេញ និងសាខាខេត្តកំពង់ចាមដែលរក្សា និងផ្តល់ការចម្លងមកវិញនូវសូហ្វែរនិងទិន្នន័យសម្រាប់ការផាត់ទាត់និងទូទាត់ចាំបាច់ដើម្បីឱ្យសភាផាត់ទាត់ជាតិដំណើរការពេញលេញឡើងវិញនៅថ្ងៃនោះ បន្ទាប់ពីមានគ្រោះមហន្តរាយណាមួយនៅសភាផាត់ទាត់ជាតិ ។

**ឆ) Back-Up Bureau Services**

សភាផាត់ទាត់ជាតិនឹងផ្តល់ការជួយសម្រួលភ្លាមៗនៅនឹងកន្លែងជា Back-Up Bureau Services នៅសភាផាត់ទាត់ជាតិចំពោះសមាជិកណាដែលមិនអាចបញ្ជូនទិន្នន័យជាអេឡិចត្រូនិកមកសភាផាត់ទាត់ជាតិបានដោយសារមូលហេតុផ្នែកប្រតិបត្តិការ។

ការជួយសម្រួលនេះផ្អែកលើការប្រើប្រាស់ Shared Client Module ។ សមាជិកដែលត្រូវការការជួយសម្រួលនេះ ត្រូវគោរពតាម Sign-On ស្តង់ដារនិងលក្ខខណ្ឌសុវត្ថិភាព ។ ការបញ្ជូននិងផ្ទេរអ៊ីនភុត/អោតភុត គឺជាការទទួលខុសត្រូវផ្ទាល់របស់អ្នកប្រើប្រាស់សេវា ។

ការបញ្ជូនអ៊ីនភុត ការបង្ហាញ ការដោះដូរ និងការបញ្ជូនអោតភុតនៃឧបករណ៍រូបវន្តមិនមែនជាផ្នែកមួយនៃប្រតិបត្តិការ ឬការទទួលខុសត្រូវរបស់សភាផាត់ទាត់ជាតិទេ ។ ការផ្ទេរមូលនិធិ ឬការជួញដូរទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ត្រូវធ្វើដោយផ្ទាល់រវាងសមាជិកផ្ទាល់និងធនាគារជាតិ ។

**១.៧- រូបិយប័ណ្ណ**

**ក) ការផាត់ទាត់ និងទូទាត់ជាប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិក**

យោងប្រកាសស្ដីពី "សភាផាត់ទាត់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិក" និងប្រកាសស្ដីពី "សភាផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល" (លេខធ៥០០-១៥០ ប្រ.ក[1] និងធ.៥០០-១៧០ ប្រ.ក[2]) សភាផាត់ទាត់ជាតិធ្វើការផាត់ទាត់និងគណនាកាតព្វកិច្ចទូទាត់សុទ្ធពហុភាគីសម្រាប់ឧបករណ៍ទូទាត់សងប្រាក់ដែលចារឹកជាប្រាក់រៀល (KHR) ឬជាប្រាក់ដុល្លារអាមេរិក (USD) ដោយឡែកពីគ្នា ។

ចំពោះការផ្ទេរឥណទានតាមប្រព័ន្ធទូទាត់រាយភ្លាមៗ ធ្វើឡើងតែជាប្រាក់រៀលប៉ុណ្ណោះ ហើយក្នុងមួយប្រតិបត្តិការមានទឹកប្រាក់ខ្ពស់បំផុត៤០លានរៀល។

សភាផាត់ទាត់ជាតិ ធ្វើការផាត់ទាត់និងរៀបចំរបាយការណ៍ទូទាត់ដែលពាក់ព័ន្ធទៅតាមរូបិយប័ណ្ណនីមួយៗដោយមិនប្ដូររូបិយប័ណ្ណដោយស្វ័យប្រវត្តិ ឬចុះឥណទានពីរូបិយប័ណ្ណមួយទៅរូបិយប័ណ្ណមួយទៀតឡើយ។ សមាជិកទាំងអស់ត្រូវបំពេញកាតព្វកិច្ចទូទាត់ជារូបិយប័ណ្ណដែលពាក់ព័ន្ធដោយអនុលោមតាមលក្ខខណ្ឌ និងខចែងអំពីលក្ខណៈសម្បត្តិប្រតិបត្តិការនិងការគ្រប់គ្រងគណនីទូទាត់ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា និងដូចមានចែងក្នុងប្រកាសលេខធ.៩-០៦-២៤០ ប្រ.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ ស្ដីពី "ប្រតិបត្តិការនៃគណនីទូទាត់" ។

**ខ) ការបញ្ជូនអ៊ីនភុត/អោតភុតពាក់ព័ន្ធនឹងរូបិយប័ណ្ណ**

សមាជិកអាចបញ្ជូនអ៊ីនភុតឧបករណ៍ទូទាត់សងប្រាក់ប្រភេទដូចគ្នាដែលចារឹកជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិកនៅក្នុងហ្វាលតែមួយទៅសភាផាត់ទាត់ជាតិ។ ឧទាហរណ៍មូលប្បទានបត្រទាំងអស់ជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិកអាចដាក់គួបសរុបនៅក្នុងហ្វាលអ៊ីនភុត ឬអោតភុតតែមួយ ។

ប៉ុន្តែឧបករណ៍ទូទាត់សងប្រាក់ដែលមានប្រភេទខុសគ្នាត្រូវដាក់ដោយឡែកពីគ្នាទៅតាមប្រភេទចំពោះរាល់ការបញ្ជូន និងការដោះដូររវាងសភាផាត់ទាត់ជាតិនិងសមាជិក ។ ឧទាហរណ៍ទិន្នន័យមូលប្បទានបត្រមិនត្រូវដាក់បញ្ចូលជាមួយទិន្នន័យបញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិកនៅក្នុងហ្វាលតែមួយឡើយ ។

[1]ប្រកាសលេខធ៥០០-១៥០ប្រ.ក ស្ដីពីសភាផាត់ទាត់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិក

[2]ប្រកាសលេខធ៥០០-១៧០ប្រ.ក ស្ដីពីសភាផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល

## ២- សមាជិកភាព

### ២.១- លក្ខណៈសម្បត្តិជាសមាជិក

គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (ស្នាក់ការកណ្តាល និងសាខានៅតាមបណ្តាខេត្ត) ដែលមានបំណងធ្វើជាសមាជិកសភាផាត់ទាត់ជាតិត្រូវមានលក្ខណៈសមស្របក្នុងការចេញផ្សាយឧបករណ៍ទូទាត់ និងត្រូវដាក់ពាក្យស្នើសុំចូលជាសមាជិក (ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ១៥ "ពាក្យស្នើសុំចូលជាសមាជិកសភាផាត់ទាត់ជាតិ" នៅធនាគារជាតិ។ ប្រសិនបើមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងបន្ទាប់ពីបានទទួលការអនុញ្ញាតពីធនាគារជាតិ គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើនោះនឹងត្រូវបានបញ្ចូលឈ្មោះជាសមាជិកសភាផាត់ទាត់ជាតិ។

គ្រឹះស្ថានធនាគារជាសមាជិកសភាផាត់ទាត់ជាតិមានសិទ្ធិជាសមាជិកប្រព័ន្ធទូទាត់រាយភ្លាមៗផង និងជាសមាជិកប្រព័ន្ធផាត់ទាត់ជាតិផង ។

ដោយឡែកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើជាសមាជិកសភាផាត់ទាត់ជាតិដែលមានសិទ្ធិប្រើតែប្រព័ន្ធទូទាត់រាយភ្លាមៗប៉ុណ្ណោះ ។

### ២.២- ការចូលជាសមាជិក

សមាជិកភាពមានពីរប្រភេទ គឺសមាជិកផ្ទាល់ និងសមាជិកមិនផ្ទាល់ ។

#### ក) សមាជិកផ្ទាល់

សមាជិកផ្ទាល់សំដៅលើគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលធ្វើប្រតិបត្តិការទូទាត់សងប្រាក់អន្តរធនាគារ និងបំពេញកាតព្វកិច្ចទូទាត់តាមរយៈសភាផាត់ទាត់ជាតិដោយប្រើគណនីទូទាត់របស់ខ្លួននៅធនាគារជាតិ ។

សមាជិកផ្ទាល់ត្រូវមាន ៖

- គណនីទូទាត់នៅធនាគារជាតិ
- កិច្ចសន្យាផ្តល់ឥណទានវិបារូបន៍ពីធនាគារជាតិ
- ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ជាស្រេច ស្របតាមស្តង់ដារបច្ចេកទេសប្រតិបត្តិការដែលកំណត់ដោយសភាផាត់ទាត់ជាតិសម្រាប់ភ្ជាប់មកប្រព័ន្ធផាត់ទាត់ជាតិនិង/ឬប្រព័ន្ធទូទាត់រាយភ្លាមៗ
- បំពេញរាល់កាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់និងបទប្បញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងការប្រើសេវាសភាផាត់ទាត់ជាតិ ។

**ខ) សមាជិកមិនផ្ទាល់**

សមាជិកមិនផ្ទាល់សំដៅលើគ្រឹះស្ថានធនាគារដែលអាចជាត់ទាត់និងទូទាត់មូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលអាចជាត់ទាត់និងទូទាត់បញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិករបស់ខ្លួនតាមរយៈសមាជិកផ្ទាល់ ដែលខ្លួនបានជ្រើសរើសដោយត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីធនាគារជាតិ។ សមាជិកមិនផ្ទាល់ត្រូវមានកិច្ចសន្យាជាមួយសមាជិកផ្ទាល់ដែលទទួលធ្វើការជាត់ទាត់និងទូទាត់កាតព្វកិច្ចជំនួសខ្លួន ហើយមិនតម្រូវឱ្យមានគណនីទូទាត់នៅធនាគារជាតិព្រមទាំងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ភ្ជាប់មកប្រព័ន្ធជាត់ទាត់ជាតិ និង/ឬប្រព័ន្ធទូទាត់រាយភ្លាមៗឡើយ ។

សមាជិកផ្ទាល់ដែលមានបំណងទទួលធ្វើការជាត់ទាត់ និងទូទាត់កាតព្វកិច្ចជួសសមាជិកមិនផ្ទាល់ក្នុងប្រព័ន្ធជាត់ទាត់ជាតិ និង/ឬប្រព័ន្ធទូទាត់រាយភ្លាមៗ ត្រូវដាក់ពាក្យស្នើសុំការយល់ព្រមពីធនាគារជាតិនូវសម្ព័ន្ធភាពរបស់ខ្លួនជាមួយសមាជិកមិនផ្ទាល់ ។ ពាក្យស្នើសុំត្រូវភ្ជាប់មកជាមួយនូវការធានាការជាត់ទាត់និងទូទាត់កាតព្វកិច្ចជួសសមាជិកមិនផ្ទាល់ និងកិច្ចសន្យារវាងធនាគារខ្លួនជាមួយសមាជិកមិនផ្ទាល់ផងដែរ ។

**គ) ការប្តូរសមាជិកភាព**

សមាជិកអាចប្តូរប្រភេទសមាជិកភាពរបស់ខ្លួនពីសមាជិកផ្ទាល់ទៅជាសមាជិកមិនផ្ទាល់ ឬពីសមាជិកមិនផ្ទាល់ទៅជាសមាជិកផ្ទាល់នៅពេលណាក៏បានដោយត្រូវស្នើសុំជាលាយលក្ខណ៍អក្សរយ៉ាងតិច១ខែមុនមកធនាគារជាតិ (សភាជាត់ទាត់ជាតិ) ។

**២.៣- ការបញ្ឈប់ជាសមាជិកភាព**

ក) សមាជិកអាចលាឈប់ដោយស្ម័គ្រចិត្តពីសភាជាត់ទាត់ជាតិដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរយ៉ាងតិច១ខែមុនដោយមានការយល់ព្រមពីធនាគារជាតិ ។

ខ) សមាជិកអាចត្រូវបានបញ្ឈប់ អនុលោមតាមលក្ខខណ្ឌដូចតទៅ ៖

- គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលត្រូវធនាគារជាតិដកហូតអាជ្ញាប័ណ្ណ

  សមាជិកទាំងឡាយណាដែលបង្កឲ្យមានការជាត់ទាត់ឡើងវិញ (Unwinding) ចំនួន២ដង (អនុវត្តចំពោះតែសមាជិកប្រព័ន្ធជាត់ទាត់ជាតិ) ។

គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលត្រូវបានបញ្ឈប់ឬលាឈប់ជាសមាជិកសភាផាត់ទាត់ជាតិ ត្រូវដោះស្រាយជាមួយសមាជិកពាក់ព័ន្ធនូវរាល់កាតព្វកិច្ចទូទាត់ដែលនៅសេសសល់ ។

## ២.៤- ការត្រៀមលក្ខណៈ និងការបំពាក់ប្រព័ន្ធសម្រាប់សមាជិក

### ក) កាតព្វកិច្ចគោរពតាមបច្ចេកទេស និងប្រតិបត្តិការ

សមាជិកអាចបង្កើតប្រព័ន្ធ "Client Module" ដោយខ្លួនឯងដែលមានលក្ខណៈប្រហាក់ប្រហែលនឹងប្រព័ន្ធ "Client Module" ដែលផ្តល់ដោយសភាផាត់ទាត់ជាតិ។ ការបង្កើតប្រព័ន្ធ "Client Module" ដោយខ្លួនឯងនេះត្រូវតែគោរពតាមលក្ខណៈសុវត្ថិភាពនិងមុខងារចាំបាច់ និងដំណើរការតាមស្តង់ដារបច្ចេកទេសនៃប្រព័ន្ធ Client Module របស់សភាផាត់ទាត់ជាតិ ។ ក្រៅពីលក្ខណៈពិសេសផ្នែកបច្ចេកទេស និងមុខងារទាំងនេះសមាជិកនីមួយៗត្រូវបញ្ជាក់ថា ប្រព័ន្ធ "Client Module" ដែលខ្លួនបានប្រើទោះជាផ្តល់ឱ្យដោយសភាផាត់ទាត់ជាតិ ឬប្រភពផ្សេងក៏ដោយត្រូវរៀបចំ ដូចតទៅ ៖

- បានតម្លើងនិងអនុវត្តយ៉ាងត្រឹមត្រូវ
- អាចបញ្ជូននិងទទួលហ្វាលនិងសារនានាដោយជោគជ័យ
- អាចបង្កើតនិង/ឬចម្លងហ្វាលសម្រាប់បញ្ជូនទៅប្រព័ន្ធ និងកន្លែងរក្សាទុកព័ត៌មានផ្សេងៗទៀតដែលស្ថិតនៅទីតាំងធ្វើប្រតិបត្តិការរបស់សមាជិក
- ធ្វើសមាហរណកម្មជាមួយប្រព័ន្ធចម្លងទុកទិន្នន័យរបស់សមាជិក និងសភាផាត់ទាត់ជាតិ
- អាចទទួលបង្ហាញ និងរក្សាទុកនូវគ្រប់របាយការណ៍ពាក់ព័ន្ធ
- អាចចូលប្រើប្រព័ន្ធនិងមើលព័ត៌មានពាក់ព័ន្ធរបស់សមាជិកនីមួយៗ និងព័ត៌មានទូទៅដែលមាននៅលើគេហទំព័រសភាផាត់ទាត់ជាតិ
- បានបញ្ចប់ការធ្វើតេស្តដោយជោគជ័យនិងមានលិខិតបញ្ជាក់ (Sign-off Letter) ។

ចំពោះប្រព័ន្ធទូទាត់រាយភ្លាមៗសមាជិកត្រូវមានប្រព័ន្ធធនាគារស្នូល (Core Banking) ដែលអាចបញ្ជូន និងទទួលហ្វាល និងសារនានាដោយស្វ័យប្រវត្តិ ។

**ខ) ការធ្វើតេស្តលើការគោរពតាមលក្ខណៈបច្ចេកទេសនិងប្រតិបត្តិការ**

ការធ្វើតេស្តតាមលក្ខណៈស្តង់ដារនិងពេលវេលានៃការធ្វើតេស្តរួមគ្នារវាងសភាផាត់ទាត់ជាតិ និងសមាជិកត្រូវកំណត់ដោយសភាផាត់ទាត់ជាតិ  ដើម្បីធានាថាទីតាំងប្រតិបត្តិការរបស់សមាជិកនីមួយៗ មានដូចតទៅ៖

- ប្រព័ន្ធ Client Module (ឬ កម្មវិធីប្រហាក់ប្រហែល) ស្របតាមការតម្រូវលើផ្នែកមុខងារ និងបច្ចេកទេសរបស់សភាផាត់ទាត់ជាតិ ។

- បានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់និងបានចូលរួមការធ្វើតេស្ត  ដើម្បីធានាថា ប្រតិបត្តិកររបស់សមាជិកដែលត្រូវបានចាត់តាំងមានសមត្ថភាព  និងអាចទុកចិត្តបានក្នុងការប្រើប្រាស់ ប្រព័ន្ធ ។

- មានសមត្ថភាពដំណើរការប្រព័ន្ធក្នុងពេលធ្វើតេស្តនៅសភាផាត់ទាត់ជាតិ ។

**គ) ការបញ្ជាក់ជូនសមាជិកនិងការត្រៀមខ្លួនដំណើរការ**

បន្ទាប់ពីការបញ្ចប់ដោយជោគជ័យនូវការធ្វើតេស្តប្រព័ន្ធដែលបានកំណត់ សភាផាត់ទាត់ជាតិ នឹងចេញលិខិតបញ្ជាក់អំពីការត្រៀមខ្លួនដំណើរការជូនសមាជិក ។ បន្ទាប់ពីការចេញលិខិតបញ្ជាក់នេះ ទិន្នន័យពាក់ព័ន្ធនឹងត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធដំណើរការរបស់សភាផាត់ទាត់ជាតិដើម្បីឱ្យសមាជិក ប្រើប្រាស់បាន ។

ប្រសិនបើសមាជិកមិនទាន់បានទទួលលិខិតបញ្ជាក់ពីធនាគារជាតិទេ សភាផាត់ទាត់ជាតិនឹង មិនទាន់ចុះបញ្ជីប្រព័ន្ធប្រតិបត្តិការរបស់សមាជិកក្នុងប្រព័ន្ធប្រតិបត្តិការរបស់សភាផាត់ទាត់ជាតិឡើយ ។ សភាផាត់ទាត់ជាតិនឹងចេញលិខិតបញ្ជាក់ថា៖

- **ការតម្លើង៖**  សមាជិកបានតម្លើងគ្រប់សមាសធាតុបច្ចេកទេសដែលពាក់ព័ន្ធនឹង ប្រព័ន្ធផាត់ទាត់ជាតិនិង/ឬ ប្រព័ន្ធទូទាត់រាយភ្លាមៗ

- **ការធ្វើតេស្ត៖**  សមាជិកបានធ្វើតេស្តពេញលេញលើហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួន និងប្រព័ន្ធ Client Module និង

- **ការទទួលយក៖** សមាជិកបានទទួលនិងឯកភាពលើការអនុវត្តតាម "វិធាននិងនីតិវិធី" របស់សភាផាត់ទាត់ជាតិ។

ក្នុងករណីមិនបានបំពេញតាមការតម្រូវខាងលើ  សមាជិកអាចនឹងត្រូវពន្យារការចូលរួម ផាត់ទាត់រហូតទាល់តែសមាជិកនោះបានបង្ហាញដោយសមស្របនូវសមត្ថភាព និងការប្រតិបត្តិតាម។

**២.៥- ការចុះឈ្មោះជាសមាជិកនិងការគាំទ្ររបស់សភាផាត់ទាត់ជាតិ**

សភាផាត់ទាត់ជាតិនឹងពិនិត្យថា សមាជិកដាក់ពាក្យសុំបានបំពេញរាល់កាតព្វកិច្ចរួមមាន ៖

**ក) ការចុះឈ្មោះ**

បញ្ចូលឈ្មោះសមាជិកជាអ្នកចូលរួមពេញសិទ្ធិទៅតាមទីតាំង (ស្នាក់ការកណ្តាលនិងសាខា) និងសិទ្ធិក្នុងការបញ្ជូនអ៊ីនភុត និងទទួលអោតភុតពីសភាផាត់ទាត់ជាតិ ។

**ខ) លេខកូដសុវត្ថិភាពនិងកូនសោសម្ងាត់ (Password and E-token)**

ផ្តល់លេខកូដសុវត្ថិភាពនិងកូនសោសម្ងាត់ដើម្បីឱ្យសមាជិកអាចចូលរួមប្រើប្រាស់ប្រព័ន្ធផាត់ទាត់ជាតិ និង/ឬ ប្រព័ន្ធទូទាត់រាយភ្លាមៗ ។

**គ) ភ្នាក់ងារទូទាត់**

សមាជិកត្រូវចុះហត្ថលេខាលើកិច្ចសន្យា "ការតែងតាំងសភាផាត់ទាត់ជាតិជាភ្នាក់ងារទូទាត់" ។

**ឃ) វិធាននិងនីតិវិធី**

សមាជិកត្រូវចុះហត្ថលេខាទទួលយក "វិធាននិងនីតិវិធី" ជាមួយសភាផាត់ទាត់ជាតិ ។

**ង) កិច្ចសន្យាសេវាសភាផាត់ទាត់ជាតិ**

សមាជិកត្រូវចុះហត្ថលេខាលើ "កិច្ចសន្យាសេវាសភាផាត់ទាត់ជាតិ" ។

**ច) សេចក្តីជូនដំណឹង និងរបាយការណ៍**

សមាជិកអាចទទួលបានសេចក្តីជូនដំណឹង និងរបាយការណ៍ផ្សេងៗរបស់ខ្លួនផ្ទាល់ដែលមាននៅលើគេហទំព័រសភាផាត់ទាត់ជាតិ ។

## ៣- តួនាទី និងការទទួលខុសត្រូវ

**៣.១- ការគ្រប់គ្រងសភាផាត់ទាត់ជាតិ**

សភាផាត់ទាត់ជាតិដឹកនាំដោយប្រធានដែលតែងតាំងដោយធនាគារជាតិដើម្បីទទួលបន្ទុកលើប្រតិបត្តិការផាត់ទាត់ប្រចាំថ្ងៃ ដូចមានចែងក្នុងប្រការ៦នៃប្រកាសស្តីពី "សភាផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល" (ធ៥០០-១៧០ប្រ.ក) និងប្រការ៦នៃប្រកាសស្តីពី "សភាផាត់ទាត់មូលប្បទានបត្រចារឹកជាដុល្លារអាមេរិក" (ធ៥០០-១៥០ប្រ.ក)។

ប្រធានសភាផាត់ទាត់ជាតិអាចប្រគល់ភារកិច្ចប្រតិបត្តិការប្រចាំថ្ងៃជូនមន្ត្រីការិយាល័យសភាផាត់ទាត់ដើម្បីទទួលបន្ទុក៖

- ជាអ្នកដឹកនាំនិងគ្រប់គ្រងការផាត់ទាត់និងទូទាត់ឧបករណ៍ទូទាត់សងប្រាក់

- ជាមន្ត្រីទំនាក់ទំនងចំពោះរាល់បញ្ហាវិវាទឬចម្ងល់ផ្សេងៗពាក់ព័ន្ធនឹងប្រតិបត្តិការប្រចាំថ្ងៃ ។

នាយកសាខាធនាគារជាតិដែលមានមណ្ឌលដោះដូរមូលប្បទានបត្រជាអ្នកដឹកនាំនិងជួយសម្របសម្រួលការដោះដូរឧបករណ៍ទូទាត់ជារូបវន្តជាមួយសមាជិកនានា ។

ប្រធានសភាផាត់ទាត់ជាតិអាចជាប្រធានគណៈកម្មាធិការប្រតិបត្តិការ ។

**៣.២- គណៈកម្មាធិការប្រតិបត្តិការសភាផាត់ទាត់ជាតិ**

**ក) រចនាសម្ព័ន្ធ**

គណៈកម្មាធិការប្រតិបត្តិការសភាផាត់ទាត់ជាតិមានប្រធាន និងអនុប្រធានដែលត្រូវបានជ្រើសរើសជារៀងរាល់ឆ្នាំដោយសមាជិក និងតែងតាំងដោយធនាគារជាតិ ។ សមាជិកទាំងអស់របស់សភាផាត់ទាត់ជាតិ ជាសមាជិករបស់គណៈកម្មាធិការនេះ ។

គណៈកម្មាធិការនេះត្រូវជួបប្រជុំរៀងរាល់ត្រីមាស ។ ការប្រជុំបន្ថែមអាចធ្វើឡើងតាមការអញ្ជើញរបស់ប្រធាន ឬតាមសំណូមពរជាលាយលក្ខណ៍អក្សររបស់សមាជិកពីររូបយ៉ាងតិចដោយត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវកម្មវត្ថុដែលត្រូវពិភាក្សា។

***ខ) មុខងារ ភារកិច្ច និងការទទួលខុសត្រូវ***

គណៈកម្មាធិការប្រតិបត្តិការមានមុខងារដូចតទៅ៖

- ផ្តល់យោបល់ដើម្បីលើកកម្ពស់គុណភាពប្រតិបត្តិការផាត់ទាត់និងប្រសិទ្ធភាពនៃការទូទាត់
- ពង្រឹងសណ្តាប់ធ្នាប់ និងវិន័យរបស់សមាជិក
- អនុវត្តឱ្យបានប្រសើរនូវភារកិច្ចដែលកំណត់ដោយធនាគារជាតិ ។

***៣.៣- ភារកិច្ចរបស់សភាផាត់ទាត់ជាតិ***

សភាផាត់ទាត់ជាតិមានភារកិច្ចដូចតទៅ ៖

**ក)** ដំណើរការប្រព័ន្ធផាត់ទាត់ជាតិនិងប្រព័ន្ធទូទាត់រាយភ្លាមៗ

**ខ)** ផ្តល់ទីកន្លែងសម្រាប់ដោះដូរមូលប្បទានបត្ររូបវន្តនៅមណ្ឌលដោះដូរមូលប្បទានបត្រដូចមានចែងក្នុងឧបសម្ព័ន្ធ១៣ "បញ្ជីឈ្មោះមណ្ឌលដោះដូរមូលប្បទានបត្រ"

**គ)** ផ្តល់ព័ត៌មាននិងមធ្យោបាយទំនាក់ទំនងដើម្បីទទួលនិងបញ្ជូនទិន្នន័យជាអេឡិចត្រូនិកពាក់ព័ន្ធនឹងឧបករណ៍ទូទាត់សងប្រាក់ និងព័ត៌មានផ្សេងៗទៀតរួមទាំង តារាងព័ត៌មានសន្ទនីយភាព

**ឃ)** រៀបចំនិងបញ្ជូនអោតភុតជាអេឡិចត្រូនិកតាមទម្រង់ស្តង់ដាររបស់ធនាគារជាតិជូនសមាជិក

**ង)** រៀបចំ និងបោះពុម្ពតារាង Check Output ដើម្បីឱ្យសមាជិកនីមួយៗអាចពិនិត្យផ្ទៀងផ្ទាត់ការប្រគល់ទទួលមូលប្បទានបត្ររូបវន្តជាមួយទិន្នន័យជាអេឡិចត្រូនិក

**ច)** បញ្ជូនប៉ុស៊ីសិនទូទាត់ដែលបានគណនាទៅសមាជិក និងការិយាល័យគ្រប់គ្រងគណនី

**ឆ)** បង្កើត ថែរក្សា និងធ្វើបច្ចុប្បន្នកម្មគេហទំព័រសភាផាត់ទាត់ជាតិ និងប្រព័ន្ធ Client Module ព្រមទាំងមុខងារពាក់ព័ន្ធដូចមានចែងក្នុងឧបសម្ព័ន្ធ១៤ "ហេដ្ឋារចនាសម្ព័ន្ធនិងសុវត្ថិភាពនៃប្រព័ន្ធផាត់ទាត់" ។

**៣.៤- តួនាទីរបស់ធនាគារជាតិនៃកម្ពុជា**

ធនាគារជាតិជាប្រតិបត្តិករប្រព័ន្ធផាត់ទាត់ជាតិនិងប្រព័ន្ធទូទាត់រាយភ្លាមៗផង និងជាសមាជិកសភាផាត់ទាត់ជាតិផង ។ ក្នុងនាមជាសមាជិកសភាផាត់ទាត់ជាតិធនាគារជាតិមានសិទ្ធិដូចតទៅ៖

- ទទួលសេវា និងប្រយោជន៍ដូចសមាជិកដទៃទៀតដែរ
- ធានាការទូទាត់របស់សមាជិកមិនផ្ទាល់របស់ខ្លួន
- បំពេញរាល់កាតព្វកិច្ចនិងគោរពតាមវិធាននិងនីតិវិធីរបស់សភាផាត់ទាត់ជាតិ ។

កាតព្វកិច្ចទូទាត់របស់ធនាគារជាតិមិនមែនជាការទទួលខុសត្រូវរបស់សភាផាត់ទាត់ជាតិឡើយ ។

**៣.៥- ការទទួលខុសត្រូវរបស់សមាជិក**

សមាជិកទាំងអស់ព្រមព្រៀងអនុវត្តនិងគោរពតាមវិធាននិងនីតិវិធីសភាផាត់ទាត់ជាតិ។ សមាជិកនីមួយៗ ទទួលខុសត្រូវចំពោះការបញ្ជូនអ៊ីនភុត ការទទួលអោតភុត ការចុះឥណទានគណនីអតិថិជននិងការជូនដំណឹង និងរបាយការណ៍ពាក់ព័ន្ធនានាដូចតទៅ៖

**៣.៥.១ ប្រព័ន្ធផាត់ទាត់ជាតិ**

**ក) ការរៀបចំអ៊ីនភុត និងអេឡិចត្រូនិកហ្វាល**

- រៀបចំឧបករណ៍ទូទាត់សងប្រាក់រូបវន្ត និងអេឡិចត្រូនិកហ្វាលសម្រាប់អ៊ីនភុត
- បញ្ជូនអ៊ីនភុតហ្វាលដែលបានរៀបចំទៅសភាផាត់ទាត់ជាតិ
- បង្ហាញឧបករណ៍ទូទាត់រូបវន្តតាមរយៈតំណាង ឬភ្នាក់ងារប្រតិស្រុតសម្រាប់ដោះដូរនៅមណ្ឌលដោះដូរមូលប្បទានបត្រតាមពេលវេលាដែលបានកំណត់ ។

**ខ) ការទទួលអោតភុត និងអេឡិចត្រូនិកហ្វាល**

- ទទួលឧបករណ៍ទូទាត់សងប្រាក់រូបវន្តដែលបានដោះដូរនៅមណ្ឌលដោះដូរមូលប្បទានបត្រ

- ទទួលពីសភាផាត់ទាត់ជាតិនូវតារាង Check Output និងអេឡិចត្រូនិកអោតភុត តាមរយៈតំណាង ឬភ្នាក់ងារប្រតិស្រុត។

**គ) ការចុះឥណទានគណនីអតិថិជន និងការជូនដំណឹង**

- ចុះឥណទានគណនីអ្នកទទួលផលក្នុងថ្ងៃប្រសិទ្ធភាព
- ជូនដំណឹងទៅអ្នកទទួលផលអំពីមូលនិធិដែលទទួលនិងអាចប្រើប្រាស់បាន ។

**ឃ) ការផ្តល់សិទ្ធិទូទាត់**

សមាជិកផ្តល់សិទ្ធិដល់សភាផាត់ទាត់ជាតិក្នុងការចុះឥណពន្ធ និងឥណទានគណនីទូទាត់របស់ខ្លួនដោយផ្អែកលើលទ្ធផលផាត់ទាត់។

**ង) ការធានាសន្ទនីយភាពសម្រាប់ការទូទាត់**

សមាជិកផ្ទាល់ត្រូវត្រៀមសន្ទនីយភាពឱ្យបានគ្រប់គ្រាន់ដើម្បីធានាកាតព្វកិច្ចទូទាត់របស់ខ្លួនឯងផងនិងរបស់សមាជិកមិនផ្ទាល់ផង ។

**ច) ការផ្ទៀងផ្ទាត់ឧបករណ៍ទូទាត់សងប្រាក់រូបវន្ត**

ឧបករណ៍ទូទាត់សងប្រាក់រូបវន្ត (មូលប្បទានបត្រ និងមូលប្បទានបត្របង្វិលវិញ) ដែលបានបង្ហាញ និងទទួលនៅមណ្ឌលដោះដូរមូលប្បទានបត្រត្រូវផ្ទៀងផ្ទាត់ជាមួយអ៊ីនភុតហ្វាល ឬអោតភុតហ្វាលជាអេឡិចត្រូនិក ។

**ឆ) ការចូលរួមដោះដូរមូលប្បទានបត្រនិងមូលប្បទានបត្របង្វិលវិញ**

សមាជិកត្រូវចូលរួមក្នុងការដោះដូរមូលប្បទានបត្រ និងមូលប្បទានបត្របង្វិលវិញនៅមណ្ឌលដោះដូរមូលប្បទានបត្រតាមពេលវេលាកំណត់ ។

**ជ) ការរក្សាទុកកំណត់ត្រានៃការទូទាត់សងប្រាក់**

សម្រាប់ការធ្វើសវនកម្ម និងការស៊ើបអង្កេតច្បាប់ចម្លងនៃកំណត់ត្រាអ៊ីនភុតនិងអោតភុតត្រូវរក្សាទុករយៈពេល១០ (ដប់) ឆ្នាំដោយគិតចាប់ពីថ្ងៃដែលបានបញ្ជូនអ៊ីនភុត ឬបានទទួលអោតភុត ។

**ឈ) ម៉ោងឈប់ទទួល (Cut-Off Time)**

- **ម៉ោងឈប់ទទួលអេឡិចត្រូនិកអ៊ីនភុត៖** ប្រព័ន្ធផាត់ទាត់ជាតិនឹងបដិសេធអេឡិចត្រូនិកអ៊ីនភុតហ្វាលនៃឧបករណ៍ទូទាត់សងប្រាក់របស់សមាជិកដែលមិនបានបញ្ជូនទាន់ពេលកំណត់

ឬពេលដែលបានឯកភាព ។ ប៉ុន្តែសមាជិកនោះនៅតែត្រូវទទួលយក និងទូទាត់នូវរាល់ឧបករណ៍ទូទាត់ទាំងនោះជារូបវន្ត និងអេឡិចត្រូនិកអោតភុតហ្វាលដែលពាក់ព័ន្ធ ។

– **ការទទួលអេឡិចត្រូនិកអោតភុតហ្វាល ៖** ការខកខានក្នុងការទទួលយកអេឡិចត្រូនិកអោតភុតហ្វាលមិនអាចជាមូលហេតុក្នុងការបដិសេធអោតភុតហ្វាលណាមួយដែលសភាផាត់ទាត់ជាតិបានបញ្ជូនមកឡើយ ។

– **ការបង្ហាញមូលប្បទានបត្រនិងមូលប្បទានបត្របង្វិលវិញ៖** សភាផាត់ទាត់ជាតិមិនអនុញ្ញាតឱ្យសមាជិកទទួលមូលប្បទានបត្រ និង/ឬមូលប្បទានបត្របង្វិលវិញរបស់សមាជិកណាដែលមិនបានបញ្ជូនអេឡិចត្រូនិកអ៊ីនភុតហ្វាលទាន់ពេលកំណត់ឡើយ ។

### ៣.៥.២ ប្រព័ន្ធទូទាត់រាយភ្លាមៗ

#### ក) ការរៀបចំអ៊ីនភុត និងអេឡិចត្រូនិកហ្វាល

- រៀបចំឧបករណ៍ទូទាត់សងប្រាក់សម្រាប់អ៊ីនភុតជាអេឡិចត្រូនិកហ្វាល
- បញ្ជូនអ៊ីនភុតហ្វាលដែលបានរៀបចំទៅសភាផាត់ទាត់ជាតិ ។

#### ខ) ការទទួលអោតភុត និងអេឡិចត្រូនិកហ្វាល

- ទទួលអោតភុតហ្វាលជាអេឡិចត្រូនិកពីសភាផាត់ទាត់ជាតិ ។

#### គ) ការចុះឥណទានគណនីអតិថិជន និងការជូនដំណឹង

**ធនាគារទទួលត្រូវ៖**

- ចុះឥណទានគណនីអ្នកទទួលផលដោយស្វ័យប្រវត្តិក្រោយពីបានទទួលអោតភុតហ្វាល ។ ក្នុងករណីដែលមិនអាចអនុវត្តកាតព្វកិច្ចនេះបាន សមាជិកត្រូវជូនដំណឹងមកសភាផាត់ទាត់ជាតិជាបន្ទាន់
- ជូនដំណឹងទៅអ្នកទទួលផលអំពីមូលនិធិដែលទទួលនិងអាចប្រើប្រាស់បានភ្លាមៗ
- ជូនដំណឹងអំពីការចុះឥណទានដោយជោគជ័យមកកាន់សភាផាត់ទាត់ជាតិ ។

#### ឃ) ការផ្តល់សិទ្ធិទូទាត់

សមាជិកផ្តល់សិទ្ធិដល់សភាផាត់ទាត់ជាតិក្នុងការចុះឥណពន្ធ និងឥណទានគណនីទូទាត់របស់ខ្លួនដោយផ្អែកលើលទ្ធផលផាត់ទាត់ ។

**ង) ការធានាសន្ទនីយភាពសម្រាប់ការទូទាត់**

សមាជិកត្រូវត្រៀមសន្ទនីយភាពឱ្យបានគ្រប់គ្រាន់ ដើម្បីធានាកាតព្វកិច្ចទូទាត់របស់ខ្លួនឯងផង និងរបស់សមាជិកមិនផ្ទាល់ផង ។

**ច) ការរក្សាទុកកំណត់ត្រានៃការទូទាត់សងប្រាក់**

សម្រាប់ការធ្វើសវនកម្ម និងការស៊ើបអង្កេត ច្បាប់ចម្លងនៃកំណត់ត្រាអ៊ីនភុត និងអោតភុតត្រូវរក្សាទុករយៈពេល១០ (ដប់) ឆ្នាំដោយគិតចាប់ពីថ្ងៃដែលបានបញ្ជូនអ៊ីនភុត ឬបានទទួលអោតភុត ។

**ឆ) ម៉ោងបញ្ជូននិងទទួលអ៊ីនភុត-អោតភុត**

ប្រព័ន្ធទូទាត់រាយភ្លាមៗដំណើរការ២៤ម៉ោងជារៀងរាល់ថ្ងៃ (២៤/៧) ។

- ការបញ្ជូនអេឡិចត្រូនិកអ៊ីនភុតហ្វាលះ សមាជិកអាចបញ្ជូនអេឡិចត្រូនិកហ្វាលមកសភាផាត់ទាត់ជាតិគ្រប់ពេល ។

- ការទទួលអេឡិចត្រូនិកអោតភុតហ្វាល ៖ សមាជិកត្រូវទទួលយកអេឡិចត្រូនិកអោតភុតហ្វាលគ្រប់ពេល ។ ការខកខានក្នុងការទទួលយកអេឡិចត្រូនិកអោតភុតហ្វាលមិនអាចជាមូលហេតុក្នុងការបដិសេធអោតភុតហ្វាលណាមួយដែលសភាផាត់ទាត់ជាតិបានបញ្ជូនមកឡើយ ។

**៣.៦- ការិយាល័យគ្រប់គ្រងគណនី**

ការិយាល័យគ្រប់គ្រងគណនីមិនមែនជាសមាជិករបស់សភាផាត់ទាត់ជាតិទេ ។ ការិយាល័យនេះផ្តល់សេវាបើកគណនីទូទាត់ដល់សមាជិក និងមានភារកិច្ចតាមដានការចុះកិច្ចបញ្ជិកាដោយស្វ័យប្រវត្តិរបស់សភាផាត់ទាត់ជាតិនូវរាល់កាតព្វកិច្ចទូទាត់របស់សមាជិកនៅក្នុងគណនីទូទាត់ ។ ចំពោះការបើក និងការប្រើប្រាស់គណនីទូទាត់សមាជិកត្រូវចុះកិច្ចព្រមព្រៀងដោយឡែកជាមួយធនាគារជាតិ ។

**៣.៧- ដែនកំណត់នៃការទទួលខុសត្រូវរបស់សភាផាត់ទាត់ជាតិ**

ការទទួលខុសត្រូវរបស់សភាផាត់ទាត់ជាតិមានដែនកំណត់ដូចខាងក្រោម ៖

**ក) កាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ** ៖ សភាផាត់ទាត់ជាតិទទួលខុសត្រូវតែលើដំណើរការផាត់ទាត់ឧបករណ៍ទូទាត់សងប្រាក់តែមិនទទួលខុសត្រូវលើតម្លៃដែលចារឹកលើឧបករណ៍ទូទាត់សងប្រាក់ដែលត្រូវផាត់ទាត់ឡើយ ។

ខ) **វិសាលភាពនៃសេវា** ៖ សភាផាត់ទាត់ជាតិផ្តល់តែសេវាផាត់ទាត់ប៉ុណ្ណោះ ។ ការបញ្ជូនអ៊ីនភុតការបង្ហាញការដោះដូរ និងការទទួលអោតភុតនៃមូលប្បទានបត្ររូបវន្តមិនមែនជាការទទួលខុសត្រូវរបស់សភាផាត់ទាត់ជាតិឡើយ។

គ) **ការប្រតិបត្តិ** (Operational Performance) ៖ សភាផាត់ទាត់ជាតិមិនទទួលខុសត្រូវចំពោះរាល់ការយឺតយ៉ាវនៃការផាត់ទាត់និងទូទាត់ដែលបណ្តាលមកពីសមាជិកណាមួយបញ្ជូនអ៊ីនភុតយឺតមកសភាផាត់ទាត់ជាតិ ។ ដោយឡែក សភាផាត់ទាត់ជាតិនឹងជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងកិច្ចដំណើរការប្រព័ន្ធ ។

## ៤- ឧបករណ៍ទូទាត់សងប្រាក់

ឧបករណ៍ទូទាត់សងប្រាក់សម្រាប់ប្រទេសកម្ពុជាមានចែងនៅក្នុងច្បាប់ស្តីពី "ឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់" ។ ការបញ្ជាក់លម្អិតអំពីទម្រង់ស្តង់ដារបច្ចេកទេសនៃឧបករណ៍ទូទាត់សងប្រាក់មានចែងនៅក្នុងប្រកាសស្តីពីមូលប្បទានបត្រស្តង់ដារ និងប្រកាសស្តីពីការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាននិងនៅក្នុងឧបសម្ព័ន្ធ៨ "ស្តង់ដារឧបករណ៍ទូទាត់សងប្រាក់" ។

ទម្រង់ទូទៅនៃឧបករណ៍ទូទាត់សងប្រាក់ដែលមិនប្រើសាច់ប្រាក់មានពីរប្រភេទ គឺមូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក។

### ៤.១- មូលប្បទានបត្រ

មូលប្បទានបត្រ ជាបញ្ជាលាយលក្ខណ៍អក្សរដោយបុគ្គលជាអ្នកចេញបញ្ជា តម្រូវឱ្យធនាគារទូទាត់សងចំនួនប្រាក់ជាកំណត់មួយឱ្យទៅ ឬតាមបញ្ជាបុគ្គលមួយទៀត ឬអ្នកកាន់ ។ មូលប្បទានបត្រត្រូវតែបានទូទាត់សងប្រាក់នៅពេលបង្ហាញ ហើយស្របតាមរាល់កាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

សភាផាត់ទាត់ជាតិនឹងប្រើទិន្នន័យមូលប្បទានបត្រជាអេឡិចត្រូនិកដែលបញ្ជូនដោយសមាជិកដើម្បីជូនដំណឹងអំពីមូលប្បទានបត្រដែលត្រូវបង្ហាញទៅធនាគារទូទាត់សង ។ ទិន្នន័យនេះក៏ត្រូវបានប្រើផងដែរ ដើម្បីគណនាប៉ូស៊ីសិនទូទាត់បណ្តោះអាសន្នប៉ូស៊ីសិនទូទាត់បង្គរ និងប៉ូស៊ីសិនទូទាត់សុទ្ធចុងក្រោយដែលកើតឡើងពីការដោះដូរមូលប្បទានបត្រ ។

ការដោះដូរមូលប្បទានបត្ររូបវន្តនៅមណ្ឌលដោះដូរមូលប្បទានបត្រត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់ជាមួយនឹងអ៊ីនភុតហ្វាល និងអោតភុតហ្វាលជាអេឡិចត្រូនិកនៃមូលប្បទានបត្រនោះ ។

**៤.២- បញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក** (ElectronicPayment Orders)

បញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកសំដៅដល់ការបញ្ជាទៅធនាគារឱ្យធ្វើការសងប្រាក់ ឬ ទារប្រាក់មួយចំនួនចេញពីគណនីដែលបានចង្អុលបង្ហាញឱ្យទៅឬសម្រាប់អ្នកទទួលប្រាក់ ឬឱ្យទៅ ឬ សម្រាប់គណនីរបស់អ្នកទទួលប្រាក់ និងរួមទាំងការកែប្រែណាមួយនៅលើបញ្ជាទូទាត់សងប្រាក់ អេឡិចត្រូនិកផងដែរ ។ បញ្ជានោះអាចមានកំណត់ថ្ងៃប្រសិទ្ធភាព ប៉ុន្តែមិនត្រូវស្ថិតនៅក្រោម លក្ខខណ្ឌណាមួយក្រៅពីអ្វីដែលធនាគារផ្តើមប្រតិបត្តិការបានព្រមព្រៀងអនុវត្តឡើយ ។

ការទូទាត់សងប្រាក់ជាអេឡិចត្រូនិក មានទម្រង់ជាបញ្ជាទូទាត់សងប្រាក់ដែលអនុញ្ញាត ឱ្យការទូទាត់សងប្រាក់អាចធ្វើឡើងដោយការចុះឥណពន្ធគណនីរបស់អ្នកផ្តើមប្រតិបត្តិការ និងចុះ ឥណទានគណនីរបស់អ្នកទទួលផល (Beneficiary) ។

បញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកមាន ការផ្ទេរឥណទាន ឥណទានផ្ទាល់ និងឥណពន្ធផ្ទាល់ ។ ប្រភេទចម្បងនៃបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកគឺ "ការផ្ទេរឥណទាន" ។

ទម្រង់ទាំងបីនៃបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកដែលត្រូវអនុវត្តមានដូចខាងក្រោម ៖

ក) **ការផ្ទេរឥណទាន (Credit Remittance)** ៖ ការផ្ទេរឥណទានត្រូវបានប្រើសម្រាប់ ការទូទាត់សងប្រាក់ដែលផ្តើមឡើងដោយអ្នកសងប្រាក់ (Payer) ទៅអ្នកទទួលផល ។

**ខ) ឥណទានផ្ទាល់** (Direct Credit) ៖ ការទូទាត់សងប្រាក់តាមរយៈឥណទានផ្ទាល់ផ្តើម ឡើងដោយអ្នកសងប្រាក់តែម្នាក់ទៅអ្នកទទួលផលមួយ ឬច្រើននាក់តាមចំនួនប្រាក់និងពេលវេលាដែល បានកំណត់ ។ ឥណទានផ្ទាល់ត្រូវបានប្រើជាទូទៅសម្រាប់ការបើកប្រាក់បៀវត្សប្រាក់សុខមាលភាព សង្គម ភាគលាភ និងការទូទាត់សងការប្រាក់។

**គ) ឥណពន្ធផ្ទាល់** (Direct Debit) ៖ ឥណពន្ធផ្ទាល់មានទម្រង់ជាប្រភេទឥណពន្ធផ្ទាល់ ដោយបង្ខំនិងដោយសំណើ។

- **ឥណពន្ធផ្ទាល់ដោយបង្ខំ** (Forced Direct Debit)

ឥណពន្ធផ្ទាល់ដោយបង្ខំជាការទូទាត់សងប្រាក់ដែលជាកាតព្វកិច្ចត្រូវទូទាត់សងភ្លាមៗ នៅពេលអ្នកទទួលផលបង្ហាញបញ្ជានេះទៅអ្នកសងប្រាក់។ ឥណពន្ធផ្ទាល់នេះអាចចេញផ្សាយ ដោយអាជ្ញាធរដែលមានសមត្ថកិច្ចតែប៉ុណ្ណោះ ដូចជា ធនាគារជាតិក្រសួង-ស្ថាប័នរដ្ឋ ឬភាគីដទៃទៀត ដែលអនុញ្ញាតដោយតុលាការ ។

- **ឥណពន្ធផ្ទាល់ដោយសំណើ** (Direct Debit Request)

ឥណពន្ធផ្ទាល់ដោយសំណើជាទម្រង់មួយនៃបញ្ជាទូទាត់សងប្រាក់ដែលមិនមានផ្ទុកតម្លៃ (Non Value Message) ។ ឥណពន្ធផ្ទាល់នេះត្រូវបានទទួលយកក្រោមរូបភាពជាសំណើ និងដំណើរការគ្រាន់តែជាសារជូនដំណឹងសម្រាប់ទូទាត់សងប្រាក់ប៉ុណ្ណោះ ។ ប្រតិបត្តិការនេះផ្តើមឡើងដោយធនាគារទទួលផលដែលជាអ្នកស្នើទៅធនាគារទូទាត់សងដើម្បីទូទាត់នៅពេលកំណត់ជាទូទៅប្រចាំខែ ដូចជាថ្លៃអគ្គិសនីនិងថ្លៃទូរស័ព្ទជាដើម ប៉ុន្តែការទូទាត់បែបនេះមានកម្រៃសេវាធនាគារខ្ពស់ជាងការទូទាត់តាម Standing Order[3] ។ នៅពេលទទួលបានឥណពន្ធផ្ទាល់ដោយសំណើ ធនាគារទូទាត់សងត្រូវរៀបចំបញ្ជាផ្ទេរឥណទានមួយដែលមានខ្លឹមសារត្រូវគ្នានឹងទិន្នន័យនៅក្នុងសារជូនដំណឹងរបស់ឥណពន្ធផ្ទាល់ដោយសំណើនេះ។

ឥណពន្ធផ្ទាល់ដោយសំណើជាកម្មវត្ថុនៃការបដិសេធដោយអ្នកសងប្រាក់ (Targeted Payer) ដើម្បីធានាកិច្ចការពារអតិថិជនឱ្យបានពេញលេញ និងបំពេញតាមកាតព្វកិច្ចធានារបស់ធនាគារ ។

## ៥- ប្រតិបត្តិការសភាផាត់ទាត់ជាតិ

### ៥.១- ថ្ងៃធ្វើការ

ចំពោះប្រព័ន្ធផាត់ទាត់ជាតិ សភាផាត់ទាត់ជាតិដំណើរការផាត់ទាត់និងទូទាត់នៅរៀងរាល់ថ្ងៃធ្វើការ លើកលែងតែមានការណែនាំផ្សេងពីនេះដោយធនាគារជាតិ ហើយមិនផ្តល់សេវាផាត់ទាត់នៅថ្ងៃឈប់សម្រាកបុណ្យជាតិ ឬថ្ងៃណាមួយដែលធនាគារជាតិប្រកាសឈប់ដោយមូលហេតុបន្ទាន់ឡើយ ។

កាលវិភាគថ្ងៃឈប់សម្រាកប្រចាំឆ្នាំនឹងមានផ្សព្វផ្សាយនៅលើគេហទំព័រសភាផាត់ទាត់ជាតិនៅរាល់មុនដំណាច់ឆ្នាំ។

ដោយឡែក ចំពោះប្រព័ន្ធទូទាត់រាយភ្លាមៗ ដំណើរការរៀងរាល់ថ្ងៃ រាប់បញ្ចូលទាំងថ្ងៃចុងសប្តាហ៍ និងថ្ងៃបុណ្យជាតិ ។

[3]ជាប្រភេទជាក់លាក់មួយនៃ "បញ្ជាទូទាត់សងប្រាក់ឥណទាន" (Credit Payment Order) ដែលការទូទាត់នេះត្រូវបានឯកភាពគ្នាជាមុន និងត្រូវបានរំពឹងថានឹងទទួលបាននូវចំនួនប្រាក់ដែលបានកំណត់តាមពេលវេលាដែលបានគ្រោងទុក ។ ជាទូទៅ ការទូទាត់បែបនេះ ត្រូវបានប្រើសម្រាប់ការចំណាយជាស្តង់ដាររបស់ឯកត្តជន និងការចំណាយជាទៀងទាត់ ដូចជា ថ្លៃជួលផ្ទះ ថ្លៃធានារ៉ាប់រង ការចំណាយសងបំណុល ផែនការសន្សំទៀងទាត់ និងការទូទាត់សងប្រាក់ការទិញជួល (Hire Purchase Payment) ។

### ៥.២- ការស្នើសុំឈប់សម្រាករបស់សមាជិក

សមាជិកដែលមានបំណងឈប់សម្រាកត្រូវស្នើសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរអំពីការឈប់សម្រាករបស់ខ្លួនមកធនាគារជាតិយ៉ាងតិចឱ្យបានមុនបីថ្ងៃនៃថ្ងៃធ្វើការ ដើម្បីធនាគារជាតិបញ្ចូលថ្ងៃឈប់សម្រាករបស់សមាជិកនោះទៅក្នុងប្រព័ន្ធផាត់ទាត់ជាតិ និងជូនដំណឹងទៅសមាជិកដទៃទៀត ។ ប៉ុន្តែ ការស្នើសុំឈប់សម្រាកនេះពុំអនុវត្តចំពោះប្រព័ន្ធទូទាត់វាយភ្លាមៗទេ គឺប្រព័ន្ធត្រូវដំណើរការដោយស្វ័យប្រវត្តិជារៀងរាល់ថ្ងៃ ។

អាសយដ្ឋានសម្រាប់ទំនាក់ទំនងជាមួយសភាផាត់ទាត់ជាតិមាននៅក្នុងឧបសម្ព័ន្ធ១៥ "អាសយដ្ឋានសម្រាប់ទំនាក់ទំនងជាមួយសភាផាត់ទាត់ជាតិ" ។ សមាជិកណាមួយដែលអវត្តមាននៅថ្ងៃផាត់ទាត់ដោយមិនបានជូនដំណឹងជាមុន សមាជិកនោះនឹងរងការពិន័យដូចមានចែងក្នុងឧបសម្ព័ន្ធ១០ "កម្រៃ សោហ៊ុយ និងការពិន័យ" ។

### ៥.៣- អវត្តមានរបស់សមាជិកនៅសភាផាត់ទាត់ជាតិ

ក្នុងករណីសមាជិកបានបញ្ជូនអ៊ីនភុតតែមិនបានចូលរួមការដោះដូរមូលប្បទានបត្រនៅគ្រាផាត់ទាត់សភាផាត់ទាត់ជាតិនឹងប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដោយផ្អែកលើអ៊ីនភុតហ្វាលរបស់សមាជិកដើម្បីអនុវត្ត ដូចខាងក្រោម៖

**ក) អវត្តមាននៅគ្រាផាត់ទាត់ទី១**

សមាជិកបង្ហាញត្រូវរក្សាមូលប្បទានប័ត្រ ដើម្បីប្រគល់ជូនសមាជិកអវត្តមាននៅគ្រាផាត់ទាត់ទី២ ។ ប្រសិនបើសមាជិកនោះអវត្តមាននៅគ្រាផាត់ទាត់ទី២ទៀត សមាជិកបង្ហាញត្រូវរក្សាទុកមូលប្បទានបត្រ ដើម្បីប្រគល់ជូនសមាជិកអវត្តមាននៅថ្ងៃផាត់ទាត់បន្ទាប់ ។

**ខ) អវត្តមាននៅគ្រាផាត់ទាត់ទី២ (មូលប្បទានបត្របង្វិលវិញ)**

ប្រសិនបើសមាជិកអវត្តមាននៅគ្រាផាត់ទាត់ទី២ សមាជិកបង្ហាញត្រូវរក្សាទុកមូលប្បទានបត្រ បង្វិលវិញដើម្បីប្រគល់ជូនសមាជិកអវត្តមាននៅថ្ងៃផាត់ទាត់បន្ទាប់ ។

ក្នុងករណីខាងលើនេះ សមាជិកនឹងរងការពិន័យដូចមានចែងក្នុងឧបសម្ព័ន្ធ១០ "កម្រៃ សោហ៊ុយ និងការពិន័យ" ។

### ៥.៤- អវត្តមានរបស់សមាជិកនៅមណ្ឌលដោះដូរមូលប្បទានបត្រ

ក្នុងករណីសមាជិកមិនបានចូលរួមការដោះដូរមូលប្បទានបត្រ មណ្ឌលដោះដូរមូលប្បទានបត្រនឹងអនុវត្ត ដូចខាងក្រោម៖

**ក) អវត្តមាននៅគ្រាផាត់ទាត់ទី១**

- ជូនដំណឹងទៅសភាផាត់ទាត់ជាតិអំពីអវត្តមានរបស់សាខាធនាគារជាសមាជិក ដើម្បីឱ្យស្នាក់ការកណ្តាលរបស់សាខាធនាគារនោះទទួលយកអោតភុតហ្វាលរបស់សាខាខ្លួនពីសភាផាត់ទាត់ជាតិ ។

- សមាជិកបង្ហាញត្រូវរក្សាមូលប្បទានបត្រ ដើម្បីប្រគល់ជូនសមាជិកអវត្តមាននៅគ្រាផាត់ទាត់ទី២ ។ ប្រសិនបើសមាជិកនោះអវត្តមាននៅគ្រាផាត់ទាត់ទី២ទៀត សមាជិកបង្ហាញត្រូវរក្សាទុកមូលប្បទានបត្រ ដើម្បីប្រគល់ជូនសមាជិកអវត្តមាននៅថ្ងៃផាត់ទាត់បន្ទាប់ ។

**ខ) អវត្តមាននៅគ្រាផាត់ទាត់ទី២ (មូលប្បទានបត្របង្វិលវិញ)**

ប្រសិនបើសមាជិកអវត្តមាននៅគ្រាផាត់ទាត់ទី២ សមាជិកបង្ហាញត្រូវរក្សាទុកមូលប្បទានបត្របង្វិលវិញ ដើម្បីប្រគល់ជូនសមាជិកអវត្តមាននៅថ្ងៃបន្ទាប់ ។

ក្នុងករណីនេះសមាជិកនឹងរងការពិន័យដូចមានចែងក្នុងឧបសម្ព័ន្ធ១០ "កម្រៃសោហ៊ុយ និងការពិន័យ" ។

**៥.៥- ម៉ោងប្រតិបត្តិការ**

សភាផាត់ទាត់ជាតិចាប់ផ្តើមដំណើរការពីម៉ោង ៧:៣០ព្រឹក ដល់ម៉ោង ១៦:៣០ រសៀល នៅរៀងរាល់ថ្ងៃធ្វើការ ។

គ្រាផាត់ទាត់នៃឧបករណ៍ទូទាត់ត្រូវបានរៀបចំដោយឡែកពីគ្នាសម្រាប់មូលប្បទានបត្រ មូលប្បទានបត្របង្វិលវិញ និងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកដូចមានចែងក្នុងឧបសម្ព័ន្ធ៩ "កម្មវិធីដំណើរការប្រចាំថ្ងៃ" ។

ចំពោះប្រព័ន្ធផាត់ទាត់ជាតិ ហ្វាលនៃបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកដែលបានបញ្ជូនមកត្រូវបានបង្គរហូតដល់ម៉ោងឈប់ទទួលសម្រាប់ផាត់ទាត់ និងត្រូវប្រើសម្រាប់គណនាប៉ូស៊ីសិនទូទាត់នៅគ្រានីមួយៗ ។ បញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកដែលបានបញ្ជូនក្រោយម៉ោងឈប់ទទួលនឹងត្រូវបង្គរសម្រាប់ផាត់ទាត់និងទូទាត់នៅគ្រាបន្ទាប់ ។

ចំពោះប្រព័ន្ធទូទាត់រាយភ្លាមៗ ហ្វាលនៃបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកដែលបានបញ្ជូនមកនឹងត្រូវប្រើសម្រាប់គណនាប៉ូស៊ីសិនទូទាត់នៅគ្រានីមួយៗ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី៩ "កម្មវិធីដំណើរការប្រចាំថ្ងៃ" ។

សមាជិកអាចតាមដានប៉ូស៊ីសិនទូទាត់បណ្តោះអាសន្នរបស់ខ្លួននៅក្នុងគ្រានីមួយៗ  រួមទាំងកាតព្វកិច្ចទូទាត់សុទ្ធតាមរយៈប្រព័ន្ធ Client Module នៃប្រព័ន្ធផាត់ទាត់ជាតិ និងប្រព័ន្ធទូទាត់រាយភ្លាមៗ ។

**៥.៦- ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃអ៊ីនកុត/អោតកុត**

សភាផាត់ទាត់ជាតិ និងសមាជិកទាំងអស់ឯកភាពគ្នាលើទម្រង់បច្ចេកទេសនិងស្តង់ដារសុវត្ថិភាពសម្រាប់អ៊ីនកុត/អោតកុត និងផ្ទៀងផ្ទាត់ទិន្នន័យឧបករណ៍ទូទាត់សងប្រាក់ ។ ដើម្បីធានានូវភាពត្រឹមត្រូវនៃប្រតិបត្តិការ  សភាផាត់ទាត់ជាតិមានគោលការណ៍ផ្ទៀងផ្ទាត់ចំនួនប្រាក់និងឧបករណ៍ទូទាត់សងប្រាក់នៅក្នុងអ៊ីនកុតហ្វាលរបស់សមាជិកដែលបានបញ្ជូននៅក្នុងគ្រាផាត់ទាត់នីមួយៗ ។ ផ្អែកលើគោលការណ៍នេះ  សមាជិកអាចអ៊ីនកុតទុកជាមុននូវទិន្នន័យឧបករណ៍ទូទាត់សងប្រាក់ប្រសិនបើចាំបាច់ដើម្បីបញ្ជូនមកសភាផាត់ទាត់ជាតិសម្រាប់ផាត់ទាត់នៅគ្រាបន្ទាប់ឬនៅថ្ងៃបន្ទាប់ ។

ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃទិន្នន័យរួមមាន ៖

**ក) ការផ្ទៀងផ្ទាត់អ៊ីនកុតដោយប្រព័ន្ធ Client Module**

ប្រព័ន្ធ Client Module ដែលបំពាក់ជូនសមាជិក  ទាមទារការអ៊ីនកុតទិន្នន័យឧបករណ៍ទូទាត់សងប្រាក់ទាំងអស់ឱ្យស្របតាមទម្រង់ស្តង់ដារបច្ចេកទេសនិងខ្លឹមសារនៃឧបករណ៍ទូទាត់សងប្រាក់នោះ ។ ប្រព័ន្ធនេះចាំបាច់ត្រូវមានហត្ថលេខាឌីជីថល (Digital Signature) ដែលបង្កើតដោយសភាផាត់ទាត់ជាតិសម្រាប់សារទូទាត់សងប្រាក់នីមួយៗ។

**ខ) ការផ្ទៀងផ្ទាត់ Batch ដោយប្រព័ន្ធ Client Module**

បន្ទាប់ពីប្រតិបត្តិកររបស់សមាជិកបានបញ្ចូលទិន្នន័យសារទូទាត់សងប្រាក់ប្រព័ន្ធ Client Module នឹងរៀបចំទិន្នន័យនេះទៅជាBatch ។ កំណត់ត្រា Header និង Trailer របស់ Batch ត្រូវបានបង្កើតដោយស្វ័យប្រវត្តិ  ប៉ុន្តែប្រតិបត្តិករចាំបាច់ត្រូវមានលេខកូដនិងលេខសម្ងាត់ (e-Token) បន្ថែមទៀតដើម្បីបញ្ជាក់អំពីការបង្កើត Batch នេះ ។

**គ) ការផ្ទៀងផ្ទាត់ហ្វាលដោយប្រព័ន្ធ Client Module**

ប្រព័ន្ធ Client Module នឹងរៀបចំ Batch ទៅជាហ្វាលដែលបានអ៊ីនគ្រីប (Encrypted) សម្រាប់បញ្ជូនមកសភាផាត់ទាត់ជាតិ ។ កំណត់ត្រា Header, Trailer និងអាសយដ្ឋានដែលត្រូវបញ្ជូន

ត្រូវបានបង្កើតដោយស្វ័យប្រវត្តិប៉ុន្តែប្រតិបត្តិករចាំបាច់ត្រូវមាន e-Token បន្ថែមទៀតដើម្បីបញ្ជាក់អំពីការបង្កើតហ្វាលនេះ ។

**ឃ) ការផ្ទៀងផ្ទាត់ហ្វាលដោយសភាផាត់ទាត់ជាតិ**

នៅពេលបានទទួលហ្វាល សភាផាត់ទាត់ជាតិនឹងឌិគ្រីប (Decrypt) ហ្វាលនេះដោយប្រើលេខកូដរបស់អ្នកផ្ញើនោះ។ ប្រសិនបើការធ្វើឌិគ្រីបបានជោគជ័យ ប្រព័ន្ធនឹងបញ្ជាក់ភាពត្រឹមត្រូវត្រឡប់ទៅវិញដោយស្វ័យប្រវត្តិ ។

**ង) ការផ្ទៀងផ្ទាត់អោតភុតហ្វាល**

អោតភុតហ្វាលដែលរៀបចំដោយសភាផាត់ទាត់ជាតិមានទម្រង់ស្របតាមស្តង់ដារ និងការផ្ទៀងផ្ទាត់ ដូចបានកំណត់ចំពោះអ៊ីនភុតហ្វាលរបស់សមាជិកដែរ លើកលែងតែលេខកូដ និងលេខរៀងប៉ុណ្ណោះដែលខុសគ្នា ។

**៥.៧- ការផាត់ទាត់ឧបករណ៍ទូទាត់សងប្រាក់**

ការផាត់ទាត់ឧបករណ៍ទូទាត់សងប្រាក់ត្រូវបានអនុវត្តដោយផ្អែកលើកំណត់ត្រាអេឡិចត្រូនិកដែលជាកំណត់ត្រាផ្លូវការ និងជាមូលដ្ឋានសម្រាប់ការផាត់ទាត់ឧបករណ៍ទូទាត់សងប្រាក់ទាំងនោះរវាងសមាជិកនានានៅសភាផាត់ទាត់ជាតិ ។

ក្នុងករណីចំនួនឧបករណ៍ទូទាត់សងប្រាក់រូបវន្តលើស ឬខ្វះការអនុវត្តមានដូចខាងក្រោម៖

- **ចំនួនឧបករណ៍ទូទាត់សងប្រាក់រូបវន្តលើស ៖** ធនាគារប្រគល់ត្រូវរក្សាទុកមូលប្បទានបត្រលើសសម្រាប់ផាត់ទាត់នៅគ្រាផាត់ទាត់លើកក្រោយ។
- **ចំនួនឧបករណ៍ទូទាត់សងប្រាក់រូបវន្តខ្វះ ៖** ធនាគារទទួលត្រូវបំពេញទិន្នន័យគ្រប់គ្រាន់លើទម្រង់ជំនួសឧបករណ៍ទូទាត់រូបវន្តដែលបាត់ សម្រាប់ជាឧបករណ៍ទូទាត់សងប្រាក់បង្វិលវិញដោយដាក់មូលហេតុថា "បាត់ឧបករណ៍ទូទាត់សងប្រាក់" ដូចមានក្នុងឧបសម្ព័ន្ធ៦ "មូលហេតុសម្រាប់ការបង្វិលវិញនូវមូលប្បទានបត្រ" និងឧបសម្ព័ន្ធ៧ "បាត់ឧបករណ៍ទូទាត់សងប្រាក់" ។

**៥.៨- អ៊ីនភុតមិនតាមស្តង់ដារបច្ចេកទេស**

ប្រព័ន្ធផាត់ទាត់ជាតិនិងប្រព័ន្ធទូទាត់រាយភ្លាមៗ មិនទទួលអ៊ីនភុតរបស់សមាជិកទាំងឡាយណាដែលមិនគោរពតាមស្តង់ដារបច្ចេកទេសទោះជាមួយផ្អែក ឬទាំងស្រុងក៏ដោយ។ ហ្វាលណាមួយដែលមានអ៊ីនភុតមិនត្រូវតាមលក្ខណៈបច្ចេកទេសនឹងធ្វើឱ្យហ្វាលនោះទាំងមូលត្រូវបានបដិសេធ។ សភាផាត់ទាត់ជាតិពុំមានសិទ្ធិតាមផ្លូវច្បាប់ក្នុងការកែប្រែអ៊ីនភុតរបស់សមាជិកទេ ។

សមាជិកនីមួយៗត្រូវតាមដានស្ថានភាពអ៊ីនភុតហ្វាលរបស់ខ្លួនដែលបានបញ្ជូននិងបញ្ជាក់ការទទួលយកអោតភុតហ្វាលពីសភាផាត់ទាត់ជាតិ និងត្រូវចាត់វិធានការសមស្របទៅតាមសារដែលបញ្ជាក់អំពីស្ថានភាពអ៊ីនភុត/អោតភុតនោះ។ ការខកខានមិនបានមើលសារជូនដំណឹងស្វ័យប្រវត្តិពីសភាផាត់ទាត់ជាតិអំពីអ៊ីនភុតដែលត្រូវបានបដិសេធ មិនអាចជាហេតុផលគ្រប់គ្រាន់ចំពោះការតវ៉ាដែលថា សភាផាត់ទាត់ជាតិមិនបានបំពេញតាមលក្ខខណ្ឌប្រតិបត្តិការរបស់ខ្លួនឡើយ ។

ទម្រង់ស្តង់ដារបច្ចេកទេសនៃអ៊ីនភុត/អោតភុតនិងស្តង់ដារសុវត្ថិភាពមានបញ្ជាក់នៅសេចក្តីណែនាំស្តីពីឯកសារណែនាំអ្នកប្រើប្រាស់ប្រព័ន្ធ Client Module (Client Module User Guide) ។

**៥.៩- ហ្វាល និង Batch**

ហ្វាលមួយអាចមាន Batch មួយ ឬច្រើនដែលផ្ទុកប្រភេទសារទូទាត់ខុសៗគ្នា ។

Batch របស់ឧបករណ៍ទូទាត់សងប្រាក់ត្រូវដាក់ដោយឡែកពីគ្នា រវាងមូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកដែលមានផ្ទុកតម្លៃនិងមិនមានផ្ទុកតម្លៃ ។

Batch របស់ឧបករណ៍ទូទាត់សងប្រាក់ត្រូវបានសំគាល់ដោយលេខកូដខុសៗគ្នាទៅតាមប្រភេទដែលបញ្ជាក់នៅលើឧបករណ៍ទូទាត់សងប្រាក់ដូចជា មូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក ។

**៥.១០- ការបញ្ជូនអ៊ីនភុតហ្វាលយឺត**

**ក). ប្រព័ន្ធផាត់ទាត់ជាតិ**

ការសុំពន្យារពេលបញ្ជូនអ៊ីនភុតហ្វាលហួសម៉ោងកំណត់ដោយសមាជិកណាមួយនឹងប៉ះពាល់ដល់កិច្ចដំណើរការប្រព័ន្ធការផាត់ទាត់និងទូទាត់របស់សមាជិកទាំងអស់ ហើយចុងក្រោយដល់អតិថិជនរបស់សមាជិក ។ ការទទួលអ៊ីនភុតយឺតត្រូវបានអនុវត្តដូចតទៅ ៖

- សមាជិកដែលបញ្ជូនអ៊ីនភុតមកក្រោយម៉ោងឈប់ទទួលដោយមិនបានសុំការអនុញ្ញាតនឹងត្រូវប្រព័ន្ធបដិសេធដោយស្វ័យប្រវត្តិ ។
- សមាជិកដែលស្នើសុំបញ្ជូនអ៊ីនភុតយឺតដោយមូលហេតុសមស្របណាមួយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកសភាផាត់ទាត់ជាតិឲ្យបានយ៉ាងតិច៣០ (សាមសិប) នាទីមុនម៉ោងឈប់ទទួលអ៊ីនភុតដើម្បីសភាផាត់ទាត់ជាតិជូនដំណឹងដល់សមាជិកផ្សេងៗទៀតអំពីការពន្យារពេលឈប់ទទួលអ៊ីនភុត។ ការពន្យារពេលនេះត្រូវបានអនុញ្ញាតចំពោះតែសមាជិកដែលបានស្នើសុំប៉ុណ្ណោះ ។

- ការបញ្ជូនអ៊ីនភុតយឺតរបស់សមាជិកដែលបានអនុញ្ញាតត្រូវអនុវត្តយ៉ាងយូរបំផុតត្រឹម៣០ (សាមសិប) នាទីក្រោយម៉ោងឈប់ទទួលអ៊ីនភុតដែលបានកំណត់ ។ ហួសពេលកំណត់នេះ ដំណើរការផាត់ទាត់នឹងត្រូវបានដំណើរការតែជាមួយសមាជិកដែលបានបញ្ជូនអ៊ីនភុតទាន់ពេលវេលាប៉ុណ្ណោះ ។ សមាជិកណាមួយដែលបញ្ជូនអ៊ីនភុតមិនទាន់ត្រូវបានអនុវត្តកាតព្វកិច្ចដូចក្នុងចំណុច៣.៥.១.ឈ ។

ការពិន័យចំពោះការបញ្ជូនអ៊ីនភុតយឺតនិងបញ្ហាផ្សេងៗទៀត មានចែងនៅឧបសម្ព័ន្ធ១០ "កម្រៃ សោហ៊ុយ និងការពិន័យៈ។

**ខ). ប្រព័ន្ធទូទាត់រាយភ្លាមៗ**

ការបញ្ជូនអ៊ីនភុតហ្វាលនៅក្នុងប្រព័ន្ធទូទាត់រាយភ្លាមៗ ពុំមានការពន្យារពេលឡើយ ។ អ៊ីនភុតហ្វាលនីមួយៗដែលបានបញ្ជូនមកដល់សភាផាត់ទាត់ជាតិប្រព័ន្ធនឹងដំណើរការបញ្ជូនសម្រាប់គ្រានីមួយៗដោយស្វ័យប្រវត្តិ ។

**៥.១១- ស្ថានភាពបន្ទាន់**

ការប្រព្រឹត្តិទៅនៃប្រតិបត្តិការផាត់ទាត់ប្រចាំថ្ងៃ អាចត្រូវបានពន្យារពេលនៅក្នុងថ្ងៃធ្វើការ ឬលើកពេល និង/ឬ ធ្វើផ្គូផ្គងជាមួយការផាត់ទាត់នៅថ្ងៃធ្វើការបន្ទាប់ប្រសិនបើប្រព័ន្ធផាត់ទាត់ជាតិ និង/ឬប្រព័ន្ធទូទាត់រាយភ្លាមៗមិនអាចដំណើរការបាន និង/ឬ សមាជិកមិនអាចបញ្ចប់ប្រតិបត្តិការផាត់ទាត់របស់ខ្លួនដែលអាចបណ្តាលមកពីករណីដូចខាងក្រោមៈ

- ករណីប្រធានសក្តិ
- ដាច់ចរន្តអគ្គិសនី
- ដាច់បណ្តាញទំនាក់ទំនង
- បញ្ហាផ្សេងៗទៀតនៅក្នុងទីក្រុង ឬក្នុងប្រទេសដែលរារាំងដល់កិច្ចដំណើរការប្រព័ន្ធ និងប្រតិបត្តិការផាត់ទាត់ ។

ក្នុងករណីនេះ សភាផាត់ទាត់ជាតិនឹងណែនាំដល់សមាជិកទាំងអស់អំពីនីតិវិធីដែលត្រូវអនុវត្ត ។ ដើម្បីធានាប្រក្រតីភាពនៃប្រតិបត្តិការរបស់ខ្លួននៅគ្រប់កាលៈទេសៈ សមាជិកនីមួយៗត្រូវមានប្រព័ន្ធគ្រប់គ្រាន់សម្រាប់ចម្លងនិងរក្សាទុកទិន្នន័យ ។

## ៦- ការទូទាត់

### ៦.១- គណនីទូទាត់និងការចុះកិច្ចបញ្ជិកាទូទាត់

គណនីទូទាត់ជាគណនីតែមួយគត់ដែលប្រើសម្រាប់ការចុះកិច្ចបញ្ជិកាឥណពន្ធ ឬឥណទានពាក់ព័ន្ធនឹងការទូទាត់របស់សមាជិកផ្ទាល់ដោយអនុលោមតាមការព្រមព្រៀងអំពីការប្រើប្រាស់គណនីទូទាត់ ។

ផ្អែកលើអ៊ីនភុតនិងអោតភុតហ្វាលដែលបានដំណើរការនៅចុងគ្រានិងនៅចុងថ្ងៃសភាផាត់ទាត់ជាតិនឹងចុះបញ្ជីដោយស្វ័តប្រវត្តិនូវកាតព្វកិច្ចទូទាត់សុទ្ធក្នុងគណនីទូទាត់ដែលមាននៅការិយាល័យគ្រប់គ្រងគណនីតាមពេលវេលាកំណត់ ។

តាមរយៈប្រព័ន្ធ Client Module សមាជិកអាចដឹងកាតព្វកិច្ចទូទាត់សុទ្ធបណ្តោះអាសន្ននិងចុងថ្ងៃរបស់ខ្លួនដែលអាចឱ្យសមាជិកងាយស្រួលក្នុងការបំពេញកង្វះសន្ទនីយភាពដើម្បីធានាការទូទាត់ប្រសិនបើមាន ។

ប្រព័ន្ធទូទាត់រាយភ្លាមៗ មានអាទិភាពទូទាត់ក្នុងគណនីទូទាត់ជាងប្រព័ន្ធដទៃទៀត ។

### ៦.២- ការតាមដានសន្ទនីយភាព

ប្រព័ន្ធ Client Module របស់សភាផាត់ទាត់ជាតិមានតារាងតាមដានសន្ទនីយភាព (Liquidity Monitoring Screen) ដែលអាចឱ្យសមាជិកមើលឃើញស្ថានភាពសន្ទនីយភាពជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិករបស់សមាជិកទាំងនៅស្នាក់ការកណ្តាល និងសាខាដែលមាននៅធនាគារជាតិនូវគណនីដូចខាងក្រោម ៖

- គណនីទូទាត់
- គណនីចរន្តនិង
- គណនីឧបករណ៍អាចជួញដូរបានចេញផ្សាយដោយធនាគារជាតិ និងរដ្ឋាភិបាល ។

បន្ទាប់ពីបានដឹងកាតព្វកិច្ចទូទាត់សុទ្ធ សមាជិកនីមួយៗចាំបាច់ត្រូវធានាសន្ទនីយភាពឱ្យបានគ្រប់គ្រាន់នៅរាល់មុនពេលទូទាត់ ។

### ៦.៣- ការមិនអាចទូទាត់បាន

#### ១). ប្រព័ន្ធផាត់ទាត់ជាតិ

ប្រសិនបើសមាជិកផ្ទាល់ពុំមានសន្ទនីយភាពគ្រប់គ្រាន់សម្រាប់បំពេញកាតព្វកិច្ចទូទាត់សុទ្ធពហុភាគីរបស់ខ្លួនតាមពេលកំណត់ក្នុងករណីចាំបាច់ ធនាគារជាតិអាចអនុវត្តដូចខាងក្រោម ៖

**ក) ពន្យារពេលបិទការទូទាត់**

ធនាគារជាតិអាចពន្យារពេលបិទការទូទាត់ដើម្បីឱ្យសមាជិកដែលខ្វះសន្ទនីយភាពមានពេលវេលាបន្ថែមក្នុងការសម្របសម្រួលរកសន្ទនីយភាពពីប្រភពផ្សេងៗសម្រាប់បំពេញកាតព្វកិច្ចទូទាត់សុទ្ធដូចជា ៖

- រកសន្ទនីយភាពពីធនាគារដទៃទៀត
- ផ្ទេរប្រាក់ពីគណនីដែលមាននៅទីស្នាក់ការកណ្តាលធនាគារជាតិទៅគណនីទូទាត់ ។

ក្នុងករណីនេះ សមាជិកដែលធ្វើឱ្យមានការពន្យារពេលបញ្ចប់ការទូទាត់នឹងត្រូវរងការពិន័យដូចមានចែងនៅក្នុងឧបសម្ព័ន្ធ១០ "កម្រៃ សោហ៊ុយ និងការពិន័យ" ។

**ខ) ការផាត់ទាត់ឡើងវិញ (Unwinding of Clearing)**

ការផាត់ទាត់ឡើងវិញជាមធ្យោបាយចុងក្រោយ ដែលអាចត្រូវបានអនុវត្តនៅពេលដែលសមាជិកផ្ទាល់ណាមួយគ្មានលទ្ធភាពរកសន្ទនីយភាពសម្រាប់បំពេញកាតព្វកិច្ចទូទាត់បានទាន់ពេលវេលា ។ ប្រសិនបើមានករណីនេះកើតឡើងការផាត់ទាត់ត្រូវធ្វើឡើងវិញ ហើយរាល់អ៊ិនភុតឧបករណ៍ ដែលត្រូវទូទាត់របស់សមាជិកទាំងអស់ត្រូវបញ្ជូនជាថ្មីមកសភាផាត់ទាត់ជាតិដើម្បីដំណើរការផាត់ទាត់ និងទូទាត់ឡើងវិញលើកលែងតែឧបករណ៍ទូទាត់របស់សមាជិកដែលគ្មានលទ្ធភាពទូទាត់សងត្រូវបានដកចេញទាំងអស់ ។

**២). ប្រព័ន្ធទូទាត់រាយភ្លាមៗ**

ប្រតិបត្តិការបញ្ជាទូទាត់របស់ប្រព័ន្ធទូទាត់រាយភ្លាមៗដំណើរការដោយផ្អែកលើសមតុល្យសរុបនៃគណនីទូទាត់ និងគណនីឥណទានវិបារូបន៍ ហើយប្រព័ន្ធទូទាត់រាយភ្លាមៗនឹងបដិសេធបញ្ជាទូទាត់ដោយស្វ័យប្រវត្តិនៅពេលដែលសមាជិកផ្តើមប្រតិបត្តិការមិនមានសន្ទនីយភាពគ្រប់គ្រាន់សម្រាប់ធ្វើការទូទាត់ ។

## ៧- របាយការណ៍និងកំណត់ត្រាសាវតារ

ក្រៅពីរក្សាទុកទិន្នន័យអ៊ិនភុតនិងអោតភុតរបស់សមាជិក ប្រព័ន្ធ Client Module អាចផ្តល់របាយការណ៍សំខាន់ៗជាទម្រង់អេឡិចត្រូនិក ដូចជា របាយការណ៍ប្រតិបត្តិការ របាយការណ៍សមិទ្ធផលប្រតិបត្តិការរបាយការណ៍ស្ថិតិ និងកំណត់ត្រាជាប្រវត្តិ។

សមាជិកអាចស្នើសុំរបាយការណ៍ផ្សេងៗដែលមាននៅក្នុងឧបសម្ព័ន្ធ១១ ពីសភាផាត់ទាត់ជាតិ ដើម្បីប្រើប្រាស់តាមការចាំបាច់ ។

**៧.១- របាយការណ៍ប្រតិបត្តិការ**

របាយការណ៍ប្រតិបត្តិការ គឺសម្រាប់ប្រើប្រាស់នៅសភាផាត់ទាត់ជាតិ និងមណ្ឌលដោះដូរមូលប្បទានបត្រ ។

របាយការណ៍ប្រតិបត្តិការប្រចាំថ្ងៃមាននៅក្នុងឧបសម្ព័ន្ធ១១ "របាយការណ៍ប្រតិបត្តិការប្រចាំថ្ងៃ" ។

ទម្រង់របាយការណ៍ប្រតិបត្តិការទាំងនេះមាននៅក្នុងឯកសារណែនាំអ្នកប្រើប្រាស់ប្រព័ន្ធ Client Module ។

**៧.២- របាយការណ៍សមិទ្ធផលប្រតិបត្តិការ**

ប្រតិបត្តិការរបស់សភាផាត់ទាត់ជាតិអាចប្រព្រឹត្តទៅដោយរលូននិងមានប្រសិទ្ធភាព អាស្រ័យលើសមិទ្ធផលប្រតិបត្តិការរបស់សមាជិកទាំងអស់ក្នុងការប្រតិបត្តិតាមយ៉ាងម៉ត់ចត់នូវលក្ខខណ្ឌ និងនីតិវិធីសុវត្ថិភាព ការរៀបចំទម្រង់ការផ្ទៀងផ្ទាត់ និងការអ៊ីនភុត/អោតភុត ។

សភាផាត់ទាត់ជាតិនឹងវាស់វែងសមិទ្ធផលប្រតិបត្តិការ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ៤ "កិច្ចសន្យាស្តីពីសេវាសភាផាត់ទាត់ជាតិ" ។

**៧.៣- របាយការណ៍ស្ថិតិ**

របាយការណ៍ស្ថិតិអាចឱ្យសមាជិកដឹងពីចំនួន និងតម្លៃសរុបឧបករណ៍ទូទាត់សងប្រាក់ដែលបានទូទាត់សងនិងបានទទួលពីសមាជិកនីមួយៗទៅតាមប្រភេទ (មូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក) ដែលដំណើរការតាមប្រព័ន្ធផាត់ទាត់ជាតិរួមទាំងសោហ៊ុយនិងកម្រៃពាក់ព័ន្ធ។

សភាផាត់ទាត់ជាតិផ្តល់របាយការណ៍ជូនសមាជិកនីមួយៗដោយឡែកពីគ្នាលើកលែងតែរបាយការណ៍ទូទាត់ដែលមានព័ត៌មានសរុបរបស់សមាជិកចូលរួមទាំងអស់ហើយសមាជិកមិនផ្ទាល់មិនអាចទទួលបានរបាយការណ៍ដោយផ្ទាល់ពីសភាផាត់ទាត់ជាតិឡើយ។

សមាជិកផ្ទាល់ដែលជាអ្នកធានានឹងទទួលរបាយការណ៍ជាក់លាក់បន្ថែមទៀតដែលបង្ហាញអំពីចំណែកកាតព្វកិច្ចទូទាត់សុទ្ធរបស់សមាជិកមិនផ្ទាល់។

**៧.៤- កំណត់ត្រាជាប្រវត្តិ (Historical Record)**

អនុលោមតាមច្បាប់ជាធរមាន សភាផាត់ទាត់ជាតិនឹងរក្សាកំណត់ត្រាជាប្រវត្តិសម្រាប់រយៈពេល១០ (ដប់) ឆ្នាំ ។ កំណត់ត្រាទូទាត់សងប្រាក់ដែលមានរយៈពេលត្រឹម៦ (ប្រាំមួយ) ខែ នឹងរក្សាទុកនៅលើគេហទំព័រសភាផាត់ទាត់ជាតិ ដើម្បីឱ្យសមាជិកដែលមានសិទ្ធិអាចចូលទៅរកទិន្នន័យរបស់ខ្លួនតែប៉ុណ្ណោះ ។ កំណត់ត្រាទូទាត់សងប្រាក់ដែលមានរយៈពេលលើសពី៦ (ប្រាំមួយ) ខែ នឹងរក្សាទុកជាឯកសារកាលប្បវត្តិ ហើយសមាជិកដែលត្រូវការកំណត់ត្រានេះត្រូវស្នើសុំទៅសភាផាត់ទាត់ជាតិ ។

កំណត់ត្រាទូទាត់សងប្រាក់ដែលមានរយៈពេលលើសពី៦ (ប្រាំមួយ) ខែ ក៏អាចរក្សាទុកនៅលើគេហទំព័រសភាផាត់ទាត់ជាតិដែរទៅតាមឆន្ទានុសិទ្ធិរបស់សភាផាត់ទាត់ជាតិ។ កំណត់ត្រាកាលប្បវត្តិនឹងរក្សាទុកនៅក្នុងឧបករណ៍ដែលទុកចិត្តបាន និងអាចចល័តបានដើម្បីរក្សាទុកកំណត់ត្រានោះឱ្យមានសុវត្ថិភាព និងអាចទាញយកមកប្រើវិញនៅពេលណាក៏បានតាមនីតិវិធីនិងមធ្យោបាយជាស្តង់ដារ ។

ដើម្បីឱ្យស្របតាមលក្ខណៈគតិយុត្តិនៃកំណត់ត្រាជាប្រវត្តិ សភាផាត់ទាត់ជាតិនឹងរក្សាទុកច្បាប់ចម្លងឯកសារដើមនៃលទ្ធផលដោះដូរឧបករណ៍ទូទាត់សងប្រាក់រវាងសមាជិកទាំងអស់បន្ថែមពីលើកំណត់ត្រាជាអេឡិចត្រូនិក ។

កំណត់ត្រាជាប្រវត្តិនេះជាកម្មសិទ្ធិរបស់សភាផាត់ទាត់ជាតិ និងត្រូវរក្សាដោយមានសុវត្ថិភាព និងជាសម្ងាត់ក្នុងរយៈពេល១០ (ដប់) ឆ្នាំ ។ ច្បាប់ចម្លងទិន្នន័យអ៊ីនភុតនិងអោតភុតដែលបានបញ្ជូននិងទទួលតាមរយៈប្រព័ន្ធ Client Module រួមទាំងរបាយការណ៍ដែលសមាជិកនីមួយៗបានទទួលជាកម្មសិទ្ធិរបស់សមាជិកពាក់ព័ន្ធ ។

## ៨- កម្រៃ សោហ៊ុយ និងការពិន័យ

**៨.១- ការបង់កម្រៃសមាជិកភាព**

សមាជិកត្រូវបង់កម្រៃសមាជិកភាពចំពោះការប្រើប្រាស់រាល់មធ្យោបាយ និងសេវាដែលផ្តល់ដោយសភាផាត់ទាត់ជាតិ។ កម្រៃសមាជិកភាពនេះត្រូវបង់តាមពេលវេលាទៀងទាត់ នៅក្នុងខែទី១ជារៀងរាល់ឆ្នាំ ។

ការបង់កម្រៃសម្រាប់សមាជិកថ្មីត្រូវបានអនុវត្តដូចតទៅ ៖

**ក)** បង់កម្រៃ ១០០% (មួយរយភាគរយ) ៖ ចំពោះគ្រឹះស្ថានធនាគារដែលបានទទួលការអនុញ្ញាតចូលជាសមាជិកសភាផាត់ទាត់ជាតិនៅក្នុងឆមាសទី១

ខ) បង់កម្រៃ ៥០% (ហាសិបភាគរយ) ៖ ចំពោះគ្រឹះស្ថានធនាគារដែលបានទទួលការអនុញ្ញាតចូលជាសមាជិកសភាផាត់ទាត់ជាតិនៅក្នុងឆមាសទី២ ។

**៨.២- ការបង់កម្រៃប្រតិបត្តិការ**

កម្រៃ និងសោហ៊ុយប្រតិបត្តិការត្រូវបានគិតដោយផ្អែកលើចំនួនឧបករណ៍ទូទាត់មួយ ឬប្រតិបត្តិការមួយទៅតាមប្រភេទឧបករណ៍ទូទាត់សងប្រាក់ដោយមិនគិតទៅលើតម្លៃចារឹកនៃឧបករណ៍នោះឡើយ ដូចមានចែងក្នុងឧបសម្ព័ន្ធ១០ "កម្រៃ សោហ៊ុយ និងការពិន័យ" ។

**៨.៣- ការពិន័យ**

ការគោរពមិនបានតាមវិធាននិងនីតិវិធីសភាផាត់ទាត់ជាតិនឹងធ្វើឱ្យមានផលប៉ះពាល់ដល់ប្រព័ន្ធសមាជិកដទៃទៀត និងទំនុកចិត្តពីទីផ្សារ ។ ដើម្បីទប់ស្កាត់ផលប៉ះពាល់ទាំងនេះ ការពិន័យត្រូវបានអនុវត្តចំពោះ ៖

**ក. ចំពោះប្រព័ន្ធផាត់ទាត់ជាតិ**

១) ភាពយឺតយ៉ាវក្នុងការបញ្ជូនអ៊ីនភុតមូលប្បទានបត្រ ឬមូលប្បទានបត្របង្វិលវិញ

២) ភាពយឺតយ៉ាវក្នុងការបញ្ជូនអ៊ីនភុតនៃបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក

៣) ការបំពេញសន្ទនីយភាពក្នុងគណនីទូទាត់។

សមាជិកណាដែលមិនបានបំពេញសន្ទនីយភាពឱ្យបានគ្រប់គ្រាន់នៅរយៈពេល ៣០ (សាមសិប) នាទីមុនគ្រាទូទាត់នីមួយៗ និងដែលចាំបាច់តម្រូវឱ្យធនាគារជាតិត្រូវផ្ទេរប្រាក់តាមលំដាប់ពី ១) គណនីចរន្ត ២) គណនីឥណទានវិបារូបន៍ ៣) គណនីមូលបត្រអាចជួញដូរបាន និង ៤) គណនីប្រាក់បញ្ញើបម្រុងកាតព្វកិច្ចរបស់សមាជិកដែលមាននៅស្នាក់ការកណ្តាលធនាគារជាតិទៅគណនីទូទាត់ សមាជិកនោះនឹងត្រូវបង់កម្រៃសេវាបំពេញសន្ទនីយភាពជាចំនួនប្រាក់ដែលបានកំណត់។

ក្នុងករណីដែលសមាជិកត្រូវបំពេញសន្ទនីយភាពគណនីទូទាត់ដោយប្រើប្រាស់គណនីប្រាក់បញ្ញើបម្រុងកាតព្វកិច្ច សមាជិកនោះអាចរងការពិន័យដោយឡែកទៀតពីធនាគារជាតិប្រសិនបើសមតុល្យក្នុងគណនីនេះមិនគ្រប់តាមគោលការណ៍កំណត់ ។

**៤) ការធ្វើឱ្យមានការពន្យារពេលបិទការទូទាត់**

សមាជិកណាមួយខ្វះសន្ទនីយភាពដែលធ្វើឱ្យសភាផាត់ទាត់ជាតិត្រូវពន្យារពេលបិទការទូទាត់និងធ្វើឱ្យប្រព័ន្ធមិនអាចបញ្ចប់តាមពេលកំណត់ សមាជិកនោះនឹងរងការពិន័យអាស្រ័យលើរយៈពេលនៃការសុំពន្យារ ។

**៥)ការធ្វើឱ្យមានការផាត់ទាត់ឡើងវិញ**

សមាជិកខ្វះសន្ទនីយភាពដែលធ្វើឱ្យការផាត់ទាត់ចាំបាច់ត្រូវដំណើរការឡើងវិញ សមាជិកនោះនឹងរងការពិន័យជាប្រាក់តាមចំនួនដែលបានកំណត់ និងអាចត្រូវសងសមាជិកដទៃទៀតនូវរាល់ចំណាយពាក់ព័ន្ធនឹងការផាត់ទាត់ឡើងវិញនេះ ។

ក្រៅពីទទួលរងការពិន័យ សមាជិកដែលធ្វើឱ្យមានដំណើរការផាត់ទាត់ឡើងវិញនឹងត្រូវរងការអនុវត្តបន្ថែមទៀត ដូចតទៅ៖

- លើកទី១ ៖ ព្យួរសមាជិកភាពរយៈពេល៣ខែ ។ ក្នុងរយៈពេលព្យួរ កាតព្វកិច្ចទូទាត់របស់សមាជិកនេះត្រូវដោះស្រាយក្រៅសភាផាត់ទាត់ជាតិ ។ ផុតរយៈពេលព្យួរនេះ សមាជិកនោះត្រូវដាក់ពាក្យចូលរួមជាសមាជិកសភាផាត់ទាត់ជាតិឡើងវិញ ប្រសិនមានបំណង ។
- លើកទី២ ៖ បញ្ឈប់សមាជិកភាពពីសភាផាត់ទាត់ជាតិ ។

ព័ត៌មានលម្អិតអំពីការពិន័យខាងលើមាននៅក្នុងឧបសម្ព័ន្ធ១០ "កម្រៃ សោហ៊ុយ និងការពិន័យ"។

**ខ. ចំពោះប្រព័ន្ធទូទាត់រាយភ្លាមៗ**

នៅគ្រាទូទាត់និមួយៗ ប្រសិនបើគណនីទូទាត់របស់សមាជិកមិនមានសន្ទនីយភាពគ្រប់គ្រាន់ ធនាគារជាតិនឹងធ្វើការផ្ទេរតាមលំដាប់អាទិភាព ១) គណនីចរន្ត ២) គណនីឥណទានវិបារូបន៍ ៣) គណនីមូលបត្រអាចជួញដូរបានដែលមិនទាន់ដាក់ធានាសម្រាប់ស្នើសុំឥណទានវិបារូបន៍ និង ៤) គណនីប្រាក់បញ្ញើបម្រុងកាតព្វកិច្ចរបស់សមាជិកដែលមាននៅស្នាក់ការកណ្តាលធនាគារជាតិ ទៅគណនីទូទាត់ សមាជិកនោះនឹងត្រូវបង់កម្រៃសេវាបំពេញសន្ទនីយភាពជាចំនួនប្រាក់ដែលបានចែងក្នុងឧបសម្ព័ន្ធ១០ "កម្រៃ សោហ៊ុយ និងការពិន័យ" ។

ក្នុងករណីដែលសមាជិកត្រូវបំពេញសន្ទនីយភាពគណនីទូទាត់ដោយប្រើប្រាស់គណនីប្រាក់បញ្ញើបម្រុងកាតព្វកិច្ច សមាជិកនោះអាចរងការពិន័យដោយឡែកទៀតពីធនាគារជាតិប្រសិនបើសមតុល្យក្នុងគណនីនេះមិនគ្រប់តាមគោលការណ៍កំណត់ ។

**៩- ក្របខ័ណ្ឌគតយុត្តពាក់ព័ន្ធ**

ប្រកាសផ្សេងៗពាក់ព័ន្ធនឹងសេវាផាត់ទាត់ និងទូទាត់ដែលមានស្រាប់ជាក្របខ័ណ្ឌគតិយុត្តិបន្ថែមទៀតសម្រាប់ទ្រទ្រង់ប្រតិបត្តិការស្នូលរបស់សភាផាត់ទាត់ជាតិ ។

រាល់កិច្ចសម្របសម្រួល និងកិច្ចសន្យាផ្សេងៗដែលមានពីមុនត្រូវចាត់ទុកជានិរាករណ៍ ។

## ឧបសម្ព័ន្ធ១ - ពាក្យបច្ចេកទេស និងនិយមន័យ

ពាក្យបច្ចេកទេសដែលប្រើនៅក្នុងវិធាននិងនីតិវិធីនេះ មាននិយមន័យដូចតទៅ ៖

- **ការផ្ទៀងផ្ទាត់សមតុល្យ** (Balance Reconciliation) ៖ សំដៅលើការពិនិត្យ និងផ្ទៀងផ្ទាត់ការបង្គរផ្នែកហិរញ្ញវត្ថុដែលត្រូវអនុវត្តសម្រាប់ភាពត្រឹមត្រូវនៃការគណនាការទូទាត់ដែលត្រូវបញ្ជូនទៅការិយាល័យគ្រប់គ្រងគណនី។

- **អ៊ីនគ្រីបឃី** (Encryption Key)៖ សំដៅលើឃីដែលប្រើសម្រាប់ប្តូរ PlainText ទៅជា Cipher Text ។ ឃីនេះមានទំនាក់ទំនងពិសេសជាមួយឌីគ្រីបឃីដែលប្រើសម្រាប់ប្តូរ Cipher Text ទៅទម្រង់ PlainText វិញ ។

- **ឌីគ្រីបឃី** (Decryption Key)៖ សំដៅលើឃីដែលប្រើសម្រាប់ប្តូរ Cipher Text ឱ្យទៅជា PlainText វិញ ។ ឃីនេះមានទំនាក់ទំនងពិសេសជាមួយអ៊ីនគ្រីបឃីដែលប្រើសម្រាប់បង្កើត Cipher Text ។

- **ការបញ្ជាក់ឌីជីថល** (Digital Certificate) ៖ សំដៅលើលេខកូដសុវត្ថិភាពឌីជីថលដែលផ្តល់ដោយសភាផាត់ទាត់ជាតិ ដើម្បីបញ្ជាក់អត្តសញ្ញាណរបស់សមាជិកដែលប្រើប្រាស់ប្រព័ន្ធ Client Module ទាំង Stand-Alone និង Shared Client Module ។

- **ហត្ថលេខាឌីជីថល** (Digital Signature) ៖ សំដៅលើការបញ្ជាក់ពីភាពត្រឹមត្រូវនៃអត្តសញ្ញាណរបស់អ្នកប្រើប្រាស់ ដើម្បីឱ្យអ្នកទទួលជឿជាក់ថា ទិន្នន័យឧបករណ៍ទូទាត់សងប្រាក់ត្រូវបានអ៊ីនគ្រីបដោយត្រឹមត្រូវ និងមិនត្រូវបានកែនៅក្នុងពេលបញ្ជូនទេ ។

- **មណ្ឌលដោះដូរមូលប្បទានបត្រ** (Check Exchange Centre) ៖ សំដៅលើស្នាក់ការ និងសាខាធនាគារជាតិដែលជាកន្លែងសម្រាប់ដោះដូរមូលប្បទានបត្ររូបវន្តរវាងសមាជិក ។

- **សភាផាត់ទាត់ជាតិ** (National Clearing House) ៖ សំដៅលើអង្គភាពមួយដែលគ្រប់គ្រងដោយធនាគារជាតិ ដើម្បីដំណើរការប្រព័ន្ធទូទាត់ជាតិ និងផ្តល់សេវាផាត់ទាត់និងទូទាត់ ដូចជាហេដ្ឋារចនាសម្ព័ន្ធ បទប្បញ្ញត្តិ វិធាននិងនីតិវិធី និងធុរកិច្ចផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសេវាផាត់ទាត់នេះ ។

- **ការផាត់ទាត់ឡើងវិញ** (Unwinding of Clearing) ៖ សំដៅលើការដំណើរការផាត់ទាត់និងទូទាត់ឡើងវិញនៅពេលដែលសមាជិកផ្ទាល់ណាមួយគ្មានលទ្ធភាពរកសន្ទនីយភាពសម្រាប់បំពេញកាតព្វកិច្ចទូទាត់បានទាន់ពេលវេលាកំណត់ ។ ការផាត់ទាត់ឡើងវិញនេះតម្រូវឱ្យសមាជិកទាំងអស់ត្រូវបញ្ជូនអ៊ីនកុតឧបករណ៍ដែលត្រូវទូទាត់ជាថ្មីមកសភាផាត់ទាត់ជាតិ ដោយដកចេញនូវទិន្នន័យឧបករណ៍ទូទាត់សងប្រាក់របស់សមាជិកដែលខ្វះសន្ទនីយភាព ។

**ឧបសម្ព័ន្ធ២ - កិច្ចសន្យាស្តីពី ការទទួលយក និងការអនុវត្តតាម "វិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ"**

# កិច្ចសន្យា

## ស្តីពី

## ការទទួលយក និងការអនុវត្តតាម "វិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ"

កិច្ចសន្យានេះធ្វើឡើងរវាង "សភាផាត់ទាត់ជាតិ" ដែលមានអាសយដ្ឋាន ២២-២៤ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ និងធនាគារឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ...................................... តទៅហៅថា "សមាជិក" ដែលមានអាសយដ្ឋាន ....................................................................................................។

ភាគី "សភាផាត់ទាត់ជាតិ" តំណាងដោយ (ឈ្មោះ............................) និង ភាគី "សមាជិក" តំណាងដោយ (ឈ្មោះ..................................................)។

ភាគីទាំងពីរបានព្រមព្រៀងតាមលក្ខខណ្ឌ និងខចែងដូចខាងក្រោម ៖

១- គោលបំណង

ការចុះហត្ថលេខាទទួលយកវិធាននិងនីតិវិធី ជាកិច្ចសន្យារួមមួយរវាងសភាផាត់ទាត់ជាតិ និងសមាជិកក្នុងការប្រើប្រាស់សេវាសភាផាត់ទាត់ជាតិ និងប្រតិបត្តិតាមខ្លឹមសារនៃវិធាននិងនីតិវិធីនេះ ដើម្បីសម្រួលដល់ដំណើរការនៃការផាត់ទាត់ និងទូទាត់តាមប្រព័ន្ធផាត់ទាត់ជាតិ និងប្រព័ន្ធទូទាត់រាយភ្លាមៗសភាផាត់ទាត់ជាតិ ។

២- ការកំណត់ក្នុងការដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់រាយភ្លាមៗ

គ្រឹះស្ថានជាសមាជិកត្រូវដាក់ឱ្យដំណើរការនូវប្រព័ន្ធទូទាត់រាយភ្លាមៗឱ្យបានត្រឹមថ្ងៃទី............ (មិនអាចលើសពី១២ខែគិតចាប់ពីថ្ងៃដាក់ពាក្យសុំចូលជាសមាជិក)

៣- ការកែប្រែ

វិធាននិងនីតិវិធីនេះអាចត្រូវបានកែប្រែ ឬធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ ។ ប្រសិនបើមានការកែប្រែវិធាននិងនីតិវិធីនេះ ឬបច្ចេកទេសស្តង់ដាររបស់ប្រព័ន្ធសភាផាត់ទាត់ជាតិនឹងជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសមាជិក ហើយសមាជិកក៏អាចជូនដំណឹងមកសភាផាត់ទាត់ជាតិវិញដែរ ប្រសិនបើមានបំណងដូចគ្នានេះ តាមរយៈសមាគមធនាគារនៅកម្ពុជា ឬសមាគមមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។

ភាគីទាំងពីរបានព្រមព្រៀងអនុវត្តតាមខ្លឹមសារដែលមានចែងខាងលើ ។

| | |
|---|---|
| ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០.... | ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០..... |
| តំណាងធនាគារជាតិនៃកម្ពុជា | តំណាងគ្រឹះស្ថានជាសមាជិក |
| អគ្គនាយកបច្ចេកទេស | ......................... |
| ...................................... | .................................. |

## ឧបសម្ព័ន្ធ៣ - កិច្ចសន្យាស្តីពី ការតែងតាំងសភាផាត់ទាត់ជាតិជាភ្នាក់ងារទូទាត់

# កិច្ចសន្យា
# ស្តីពី

# ការតែងតាំងសភាផាត់ទាត់ជាតិជាភ្នាក់ងារទូទាត់

ឈឈឈ*៥៥៥

កិច្ចសន្យានេះធ្វើឡើងរវាង "សភាផាត់ទាត់ជាតិ" ដែលមានអាសយដ្ឋាន ២២-២៤ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ និងធនាគារឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ...................................... តទៅហៅថា "សមាជិក" ដែលមានអាសយដ្ឋាន .................................................................................................។

ភាគី "សភាផាត់ទាត់ជាតិ" តំណាងដោយ (ឈ្មោះ...........................) និងភាគី "សមាជិក" តំណាងដោយ (ឈ្មោះ.........................................)។

ភាគីទាំងពីរបានព្រមព្រៀងតាមលក្ខខណ្ឌ និងខចែងដូចខាងក្រោម ៖

**១) គោលបំណង**

ការតែងតាំងសភាផាត់ទាត់ជាតិជាភ្នាក់ងារទូទាត់ គឺដើម្បីជួយសម្រួលដល់ប្រតិបត្តិការពាក់ព័ន្ធនឹងការផាត់ទាត់និងទូទាត់នូវរាល់ឧបករណ៍ទូទាត់សងប្រាក់ទាំងអស់ រួមទាំងការទទួលអ៊ីនភុតហ្វាល ការបញ្ជូនអោតភុតហ្វាលទៅសមាជិក និងព័ត៌មានអំពីកាតព្វកិច្ចទូទាត់សុទ្ធជាពហុភាគីរបស់សមាជិកនីមួយៗទៅការិយាល័យគ្រប់គ្រងគណនីដើម្បីចុះកិច្ចបញ្ជិកាទូទាត់ដោយស្វ័យប្រវត្តិ ។

កិច្ចសន្យានេះតម្រូវឱ្យសមាជិកទាំងអស់ព្រមព្រៀង និងអនុវត្តតាមការតែងតាំងនិងប្រគល់សិទ្ធឱ្យសភាផាត់ទាត់ធ្វើជាភ្នាក់ងារទូទាត់ ។

**២) ភារកិច្ចរបស់ភ្នាក់ងារទូទាត់**

ភ្នាក់ងារទូទាត់មានភារកិច្ច ដូចខាងក្រោម ៖

ក) ទទួលអ៊ីនភុតពីសមាជិក

ខ) ផ្តល់អោតភុតជូនសមាជិកសម្រាប់ផ្ទៀងផ្ទាត់

គ) ការដោះដូរឧបករណ៍ទូទាត់សងប្រាក់រូបវន្ត ( សម្រាប់សមាជិកប្រព័ន្ធផាត់ទាត់ជាតិ )

ឃ) ជូនដំណឹងទៅការិយាល័យគ្រប់គ្រងគណនីអំពី កាតព្វកិច្ចទូទាត់សុទ្ធពហុភាគីរបស់សមាជិកនៅគ្រាទូទាត់នីមួយៗ ។

**៣) ភារកិច្ចរបស់សមាជិក**

ដើម្បីឱ្យភ្នាក់ងារទូទាត់បំពេញភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព សមាជិកមានភារកិច្ចប្រតិបត្តិតាមវិធាននិងនីតិវិធីសភាផាត់ទាត់ជាតិ និងធានាភាពគ្រប់គ្រាន់នៃសន្ទនីយភាពនៅក្នុងគណនីទូទាត់របស់ខ្លួន ។

ភាគីទាំងពីរបានព្រមព្រៀងអនុវត្តតាមខ្លឹមសារដែលមានចែងខាងលើ ។

| | |
|---|---|
| ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០.... | ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០....... |
| តំណាងធនាគារជាតិនៃកម្ពុជា | តំណាងគ្រឹះស្ថានជាសមាជិក |
| អគ្គនាយកបច្ចេកទេស | .......................... |
| ...................................... | .................................. |

**ឧបសម្ព័ន្ធ៤ - កិច្ចសន្យាស្តីពី សេវាសភាផាត់ទាត់ជាតិ**

**កិច្ចសន្យា**

**ស្តីពី**

**សេវាសភាផាត់ទាត់ជាតិ**

៚៚៚*៛៛៛

កិច្ចសន្យានេះធ្វើឡើងរវាង "សភាផាត់ទាត់ជាតិ" ដែលមានអាសយដ្ឋាន ២២-២៤ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ និងធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ...................... ................. តទៅហៅថា "សមាជិក" ដែលមានអាសយដ្ឋាន.................................................. ...........................................................................................។

ភាគី "សភាផាត់ទាត់ជាតិ" តំណាងដោយ (ឈ្មោះ...............................) និងភាគី "សមាជិក" តំណាងដោយ (ឈ្មោះ....................................) ។

ដើម្បីឱ្យការអនុវត្តរបស់សភាផាត់ទាត់ជាតិមានរបៀបរៀបរយល្អ ភាគីទាំងពីរបានព្រមព្រៀងអនុវត្តតាមលក្ខខណ្ឌ និងខចែងដូចខាងក្រោម ៖

**១) គោលបំណង**

កិច្ចសន្យាសេវារវាងសភាផាត់ទាត់ជាតិ និងសមាជិកកំណត់កម្រិតគោលដែលត្រូវសម្រេច និងជាក្របខ័ណ្ឌសម្រាប់វាស់វែងការអនុវត្តដែលជាឧបករណ៍គ្រប់គ្រងទូទៅមួយសម្រាប់ភាគីទាំងអស់ ។ កិច្ចសន្យាសេវានេះ គឺសម្រាប់វាយតម្លៃអំពីការអនុវត្តចំពោះសេវា មធ្យោបាយ និងរាល់ដំណើរការដែលមានចែងក្នុង "វិធាននិងនីតិវិធីសភាផាត់ទាត់ជាតិ" ។

**២) ការវាស់វែងការអនុវត្ត**

សភាផាត់ទាត់ជាតិ និងសមាជិកទាំងអស់នឹងអនុវត្តនិងរក្សាកម្រិតស្តង់ដាររបស់សភាផាត់-ទាត់ជាតិដើម្បីឱ្យការអនុវត្តសម្រេចបាន ៩៥% នៃរង្វាស់គោល ១០០% ។ ការអនុវត្តប្រចាំថ្ងៃ ត្រូវបានគណនាដោយធៀបនឹងកម្រិតគោលសម្រាប់ដំណើរការប្រចាំថ្ងៃ ដូចខាងក្រោម ៖

- ពេលវេលាផាត់ទាត់និងទូទាត់ជាក់ស្តែង ៨០%
- ពេលវេលាចាប់ផ្តើមជាក់ស្តែងក្នុងថ្ងៃ ៥%
- ម៉ោងឈប់ទទួលអ៊ីនភុត ៥%
- ពេលវេលាទូទាត់ជាក់ស្តែង ៥%

- បញ្ហាផ្សេងៗនៃកិច្ចដំណើរការជាក់ស្តែងដែលកើតឡើងដោយសារការធ្វើបច្ចុប្បន្នកម្ម និងការផ្លាស់ប្តូរកម្មវិធី ៥% ។

សភាជាត់ទាត់ជាតិនឹងរាយការណ៍អំពីលទ្ធផលនៃការអនុវត្តនៅរៀងរាល់ឆមាស ។

**៣)លក្ខខណ្ឌ និងខចែង**

កិច្ចសន្យាសេវាសភាជាត់ទាត់ជាតិនេះ ជាចំណងផ្លូវច្បាប់របស់ភាគីទាំងពីរ ប៉ុន្តែមិនមានការពិន័យឬដំណោះស្រាយជាហិរញ្ញវត្ថុទេ ប្រសិនបើការអនុវត្តមិនអាចសម្រេចបានតាមគោលដៅ ។ ភាគីពាក់ព័ន្ធអាចពិភាក្សាដើម្បីកែប្រែកិច្ចសន្យាសេវានេះ ដោយត្រូវមានការឯកភាពពីសភាជាត់ទាត់ជាតិ ។

ភាគីទាំងពីរបានព្រមព្រៀងអនុវត្តតាមខ្លឹមសារដែលមានចែងខាងលើ ។

| | |
|---|---|
| ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០..... | ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០...... |
| តំណាងធនាគារជាតិនៃកម្ពុជា | តំណាងគ្រឹះស្ថានជាសមាជិក |
| អគ្គនាយកបច្ចេកទេស | .......................... |
| ...................................... | .................................. |

## ឧបសម្ព័ន្ធ៥ - ពាក្យស្នើសុំចូលជាសមាជិកសភាផាត់ទាត់

### ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ
### ពាក្យសុំចូលជាសមាជិកសភាផាត់ទាត់ជាតិ

ឈ្មោះធនាគារឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ :.............................................
ឈ្មោះអ្នកសុំ : ..................................................................................................
ឋានៈ : ..................................................................................................
អាសយដ្ឋានគ្រឹះស្ថាន:............................................................................................
អាសយដ្ឋានប្រៃសណីយ៍:...........................................................................................
ទូរស័ព្ទ : ..................................................................................................

### សូមគោរពជូន
### លោកជំទាវអគ្គនាយកបច្ចេកទេស និងជាប្រធានគណៈកម្មាធិការ
### ប្រតិបត្តិការសភាផាត់ទាត់ជាតិ

ក្រោយពីបានស្វែងយល់ប្រកាសលេខធ.៥.០០-១៧០ប្រក. ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០ ស្តីពីសភាផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល និងប្រកាសលេខធ.៥.០០.១៥០ប្រក. ចុះថ្ងៃ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីសភាផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់ដុល្លារអាមេរិក និង វិធាននិងនីតិវិធីសភាផាត់ទាត់ជាតិ ដើម្បីសម្រួលដល់ការទូទាត់មូលប្បទានបត្រ និងឧបករណ៍ទូទាត់សងប្រាក់ជាអេឡិចត្រូនិករវាងធនាគារយើងខ្ញុំជាមួយនឹងគ្រឹះស្ថានធនាគារដទៃទៀត យើងខ្ញុំសុំស្នើលោកជំទាវមេត្តាពិនិត្យ និងអនុញ្ញាតឱ្យធនាគារ/សាខាធនាគារ.....................................បានចូលជាសមាជិកសភាផាត់ទាត់ជាតិ៖

ប្រព័ន្ធផាត់ទាត់ជាតិ ☐
- Stand-alone Client Module☐
- Shared Client Module☐

ប្រព័ន្ធទូទាត់រាយភ្លាមៗ ☐
- Stand-alone Client Module☐
- Shared Client Module☐

យើងខ្ញុំសន្យាអនុវត្តតាមយ៉ាងម៉ឺងម៉ាត់នូវប្រកាស និងវិធាននិងនីតិវិធីសភាផាត់ទាត់ជាតិ ពាក់ព័ន្ធនឹងការទូទាត់ ។

សូមលោកជំទាវ ទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី ...........ខែ ........... ឆ្នាំ២០

**ហត្ថលេខា និងត្រា**

យើងខ្ញុំសូមជូនភ្ជាប់ជាមួយនូវ:

| | | |
|---|---|---|
| -ច្បាប់ចតចម្លងនៃអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារ | ១ | ច្បាប់ |
| -លិខិតឧទ្ទេសនាម និងគំរូហត្ថលេខាតំណាងចូលរួមផាត់ទាត់ | ១ | ច្បាប់ |
| - កិច្ចសន្យាផ្តល់ឥណទានវិបារូបន៍ | ១ | ច្បាប់ |
| - គណនីទូទាត់នៅធនាគារជាតិ | ១ | ច្បាប់ |

## ឧបសម្ព័ន្ធ៦ - មូលហេតុសម្រាប់ការបង្វិលចេញនូវមូលប្បទានបត្រ

ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់មាត្រា៤ ចែងថា មូលប្បទានបត្រអាចត្រូវបានសរសេរជាអក្សរខ្មែរ ឬជាអក្សរបរទេស និងត្រូវមាននិទ្ទេស ដូចខាងក្រោម ៖

- ពាក្យថា មូលប្បទានបត្រដែលចារឹកជាភាសាណាមួយដែលប្រើក្នុងការចេញឧបករណ៍នេះ
- បញ្ជាដោយឥតលក្ខខណ្ឌឱ្យទូទាត់សងចំនួនប្រាក់ជាកំណត់មួយ
- ឈ្មោះរបស់បហារិតដែលជាធនាគារត្រូវទូទាត់សងប្រាក់
- កន្លែងដែលត្រូវធ្វើការទូទាត់សងប្រាក់
- កាលបរិច្ឆេទ និងទីកន្លែងដែលមូលប្បទានបត្រត្រូវបានចេញ
- ហត្ថលេខារបស់បហារកដែលជាបុគ្គលចេញបញ្ជាលើមូលប្បទានបត្រ ។

បុគ្គលិកនិងអតិថិជនរបស់ធនាគារត្រូវដឹងអំពីការតម្រូវផ្នែកគតិយុត្តិជាអប្បបរមាទាំងនេះ ។ ប្រសិនបើមូលប្បទានបត្រមិនមាននិទ្ទេសត្រឹមត្រូវដូចខាងលើមួយ ឬច្រើន សភាផាត់ទាត់ជាតិនឹងបោះត្រា "បង្វិលវិញ" នៅលើមូលប្បទានបត្រនោះ ហើយការពិន័យនឹងត្រូវបានអនុវត្តចំពោះសមាជិកណាដែលចេញផ្សាយ និងទទួលយកមូលប្បទានបត្រដោយគ្មានការប្រុងប្រយ័ត្ន ។

លេខកូដសម្គាល់មូលប្បទានបត្របង្វិលវិញដោយសារមូលហេតុខាងលើ ឬមូលហេតុផ្សេងទៀត និងការពិន័យមូលប្បទានបត្របង្វិលវិញនេះចំពោះសមាជិកមាន ដូចខាងក្រោម ៖

លេខកូដមូលហេតុនិងការពិន័យមូលប្បទានបត្របង្វិលវិញ

| លេខកូដ | មូលហេតុ | ការបង់ពិន័យ | | ផ្សេងៗ |
|---|---|---|---|---|
| | | ធនាគារទទួល | ធនាគារបង្ហាញ | |
| *មូលនិធិ* | | | | |
| ០១ | មូលនិធិមិនគ្រប់គ្រាន់ ឬគ្មានមូលនិធិ | ✓ | | |
| ០២ | មូលនិធិមិនទាន់បានជំរះ | ✓ | | |
| *ការទូទាត់សងប្រាក់ឬគណនីមិនមានសុពលភាព* | | | | |

| | | | | |
|---|---|---|---|---|
| ០៦ | គណនីត្រូវបានបិទ | ✓ | | |
| ០៧ | គ្មានគណនី | ✓ | | |
| ០៨ | ការទូទាត់សងប្រាក់ត្រូវបានបញ្ឈប់ | ✓ | | |
| ០៩ | គណនីឃាត់ទុក | ✓ | | |
| ១០ | បហារ័កក្ស័យធន ឬត្រូវជំរះបញ្ជី | ✓ | | |
| *ព័ត៌មានមិនពេញលេញលើមូលប្បទានបត្រ* | | | | |
| ២០ | គ្មានហត្ថលេខាបហារ័ក | ✓ | ✓ | Not compliant with minimal legal requirements<br>មិនស្របតាមលក្ខខណ្ឌគតិយុត្តិអប្បបរមា |
| ២១ | ខ្វះហត្ថលេខាបហារ័កបន្ថែមដែលចាំបាច់ | ✓ | | |
| ២២ | ហត្ថលេខាបហារ័កខុសពីគំរូហត្ថលេខា | ✓ | | |
| ២៣ | ខ្វះហត្ថលេខាបហារ័កដែលចាំបាច់ចំពោះការផ្លាស់ប្តូរ | ✓ | | |
| ២៤ | ខ្វះត្រា | ✓ | | |
| ២៥ | ត្រាខុសពីត្រាគំរូ | ✓ | | |
| ២៦ | ខ្វះចំនួនប្រាក់ជាអក្សរ | ✓ | ✓ | Not compliant with minimal legal requirements<br>មិនស្របតាមលក្ខខណ្ឌគតិយុត្តិអប្បបរមា |
| ២៧ | គ្មានកាលបរិច្ឆេទ | ✓ | ✓ | Not compliant with minimal legal requirements<br>មិនស្របតាមលក្ខខណ្ឌគតិយុត្តិអប្បបរមា |
| ២៨ | កាលបរិច្ឆេទមិនត្រឹមត្រូវ | ✓ | | Date written is not in dd/mm/yy format<br>សរសេរកាលបរិច្ឆេទខុសទម្រង់ |

| | | | | |
|---|---|---|---|---|
| ២៩ | ហួសសុពលភាព | | ✓ | Check is presented more than 6 months after issued date មូលប្បទានបត្រត្រូវបានបង្ហាញលើសរយៈពេលកំណត់ ៦ខែ |
| ៣០ | ការប្រើប្រាស់ទម្រង់មិនត្រឹមត្រូវ | ✓ | | ឧទាហរណ៍៖<br>១) ប្រើទម្រង់មូលប្បទានបត្រដុល្លារអាមេរិកសម្រាប់ទូទាត់ប្រាក់រៀល<br>២) សរសេរលើបន្ទាត់លេខកូដ MICR |
| *កំហុសឆ្គងក្នុងការដោះដូរ* | | | | |
| ៤០ | ធនាគារទទួលអវត្តមានក្នុងគ្រាដោះដូរមូលប្បទានបត្ររូបវន្ត | ✓ | | បង្វិលវិញដោយមណ្ឌលដោះដូរមូលប្បទានបត្រក្នុងនាមជាភ្នាក់ងារសម្រាប់ធនាគារដែលអវត្តមាននៅគ្រាដោះដូរមូលប្បទានបត្ររូបវន្ត |
| ៤១ | ផ្សេងៗ | ✓ | | |
| ៤២ | ទិន្នន័យនៅលើមូលប្បទានបត្រនិងទិន្នន័យអេឡិចត្រូនិកមិនស៊ីគ្នា | | ✓ | |
| ៤៣ | មូលប្បទានបត្រខ្មៅចខ្មី | | ✓ | |
| ៤៤ | Missing Item – mislaid by the Presenting Bank មូលប្បទានបត្របាត់ដោយធនាគារបង្ហាញ | | ✓ | |
| ៤៥ | Missing Item – mislaid after receipt by the Receiving Bank មូលប្បទានបត្របាត់ដោយធនាគារទទួលបន្ទាប់ពីបាន | ✓ | | |

| | | | | |
|---|---|---|---|---|
| | ទទួល | | | |
| ៤៦ | Incorrect receiving Bank ប្រគល់ខុសធនាគារទទួល | | ✓ | |

# NATIONAL BANK OF CAMBODIA

# NATIONAL CLEARING HOUSE RULES AND PROCEDURES

## Preamble:

The Rules and Procedures of the National Clearing House are organized to provide for the operation of clearing and settlement and for the smooth operation and management of the National Clearing House. The Rules and Procedures play a very critical role in enabling the Members to understand the operations functionalities and role of the member and the National Clearing House. The Members of the National Clearing House shall implement and comply with these Rules and Procedures.

The purpose of this document is to provide the implementation details of the National Clearing House Operations and guidance regarding the rights and obligations of each Member. Therefore, this document outlines the roles of the Members and Management of the National Clearing House. In particular, this document provides for the formal agreements between the National Clearing House and each Member in respect of i) the "Rules and Procedures" ii) Appointment of the National Clearing House as Settlement Agent, and iii) the National Clearing House "Service Level Agreement".

Every Member in the National Clearing House shall be legally bound by these Rules and Procedures.

## Contents

1. INTRODUCTION ........ 1
1.1 Purposes ........ 1
1.2 Governing Law ........ 1
1.3 Obligations ........ 1
a. Agreement ........ 1
b. User Connectivity and Readiness ........ 1
1.4 Appointment of the National Clearing House as Settlement Agent ........ 2
1.5 National Clearing House Service Level Agreement ........ 2
1.6 National Clearing House Services ........ 2
a. Physical Check Exchanges ........ 3
b. Electronic Exchanges ........ 3
c. Management of Physical and Electronic Exchanges ........ 3
d. Help Desk ........ 3
e. Solution to dispute ........ 3
f. Back-Up Facilities ........ 3
g. Back-Up Bureau Services ........ 4
1.7 Currencies ........ 4
a. KHR and USD Clearing and Settlement ........ 4
b. Support for Mixed Currency Input/Output ........ 4
2. MEMBERSHIP ........ 5
2.1 Qualifications for Participation ........ 5
2.2 Admission of a Member ........ 5
a. Direct Member ........ 5
b. Indirect Member ........ 5
c. Changing Membership ........ 6
2.3 Termination of Membership ........ 6
2.4 Member Set-Up and Readiness ........ 6
a. Technical and Operational Compliance Requirements ........ 6
b. Technical and Operational Compliance Testing ........ 6
c. Member Certification and Operational Readiness ........ 7
2.5 Member Registration and Support by the National Clearing House ........ 7
3. ROLES AND RESPONSIBILITIES ........ 8
3.1 National Clearing House Management ........ 8
3.2 National Clearing House Operations Committee ........ 8
a. Organisation ........ 8
b. Functions duties and responsibilities ........ 8
3.3 National Clearing House Responsibilities ........ 8

3.4 Functions of National Bank of Cambodia .... 9
3.5 Member Responsibilities .... 9
a. Preparation of Input and Electronic Files .... 9
b. Acceptance of Output and Electronic Files .... 9
c. Settlement Authorization and Notification .... 9
d. Authorization .... 10
e. Assurance of Settlement Liquidity .... 10
f. Reconciliation of Physical Items .... 10
g. Attendance for Check and Returned Check Exchanges .... 10
h. Retention of Payment Records .... 10
i. Cut-Off Times .... 10
3.5.2 FAST System .... 10
a. Preparation of Input and Electronic Files .... 10
b. Acceptance of Output and Electronic Files .... 10
c. Settlement Authorization and Notification .... 10
d. Authorization .... 11
e. Assurance of Settlement Liquidity .... 11
f. Retention of Payment Records .... 11
g. Cut-Off Times .... 11
3.6 Accounting Management Division .... 11
3.7 Limitations of National Clearing House Liability .... 11
4. PAYMENT INSTRUMENTS .... 11
4.1 Checks .... 12
4.2 Electronic Payment Orders .... 12
5. NATIONAL CLEARING HOUSE OPERATION .... 13
5.1 Business Days .... 13
5.2 Specific Member Holidays .... 13
5.3 Absence of member from the National Clearing House .... 13
5.4 Absence of Member From the Check Exchange Centre .... 14
5.5 Hours of Operation .... 14
5.6 Input/ Output Validation .... 15
5.7 The Clearing of Payment Instruments .... 15
5.8 Non-Compliant Input .... 16
5.9 Files And Batches .... 16
5.10 Late Input .... 16
a. National Clearing System .... 16
b. FAST System .... 16
5.11 Emergency Conditions .... 17

6. SETTLEMENT .......... 17
6.1 Settlement Accounts and Settlement Posting .......... 17
6.2 Settlement Liquidity Monitoring .......... 17
6.3 Failure to Settle .......... 18
1/- National Clearing System .......... 18
2/- FAST System .......... 18
7. REPORTING AND HISTORICAL RECORDS .......... 18
7.1 Operational Reports .......... 18
7.2 Operational Performance Report .......... 18
7.3 Statistics .......... 19
7.4 Historical Records .......... 19
8. FEES, CHARGES AND PENALTIES .......... 19
8.1 Membership Fees .......... 19
8.2 Operational Fees .......... 19
8.3 Penalties .......... 20
a) National Clearing System .......... 20
b). Fast System .......... 20
9. ACCEPTANCE OF THE RULES AND PROCEDURES .......... 21
Appendix 1 - Technical Terms and Definitions .......... 22
Appendix 2 - Acceptance and Observance of the "Rules and Procedures" Agreement .......... 23
Appendix 3 - Appointment of the National Clearing House as Settlement Agent .......... 24
Appendix 4 - Service Level Agreement .......... 25
Appendix 5 – National Clearing House Membership Application Form .......... 26
Appendix 6 - Reasons for Return of Checks .......... 27
Appendix 7 - Missing Items .......... 29
Appendix 8 - Payment Instrument Standards .......... 30
Appendix 9 - Daily Processing Schedule .......... 33
Appendix 10- Fees, Charges and Penalties .......... 34
Appendix 11 - Daily Operational Reports .......... 37
Appendix 12–Setting-up and operating the client module system .......... 44
Appendix 13 - List of Regional Check Exchange Centres .......... 50
Appendix 14- Infrastructure and security of the National Clearing system .......... 51
Appendix 15 - Addresses for Notices .......... 53

# 1. INTRODUCTION

## 1.1 PURPOSES

The Rules and Procedures shall govern the operations of the National Clearing House and shall be implemented by Members in issuing, accepting and/or processing checks and other payment instruments in the clearing and settlement process; and other matters relevant to those payment instruments. The Rules and Procedures are for the smoothly operation and management of the National Clearing House and they shall be legally binding on all Members.

- The Clearing House which is managed by the National Bank of Cambodia is hereby called "National Clearing House"
- The Rules and Procedures of the National Clearing House hereby called "Rules and Procedures"
- The Members of the National Clearing House hereby called "Member".

## 1.2 GOVERNING LAW

These Rules and Procedures are prepared in compliance with the Law and relevant Prakas on the Payment Instrument.

All the provisions of the "Rules and Procedures" and all subsequent updates, amendments and changes shall be subjected to the laws of the Kingdom of Cambodia and all other published regulations of the National Bank of Cambodia.

## 1.3 OBLIGATIONS

Each Member has the following obligations:

### a. Agreement

Each Member is required to sign all agreements with the National Clearing House in respect of the following:

- National Clearing House Rules and Procedures
- Appointment of the National Clearing House as Settlement Agent

  (Details is contained in Appendix 2)
- National Clearing House Service Level Agreement (Details is contained in Appendix 3).

### b. User Connectivity and Readiness

Every Member shall select their connectivity and infrastructure requirements and complete all related Set-Up, testing and acceptance of the option(s) selected. There are two options of connectivity: Shared Client Module and Stand Alone Client Module.

- SHARED CLIENT MODULE – This option supports only one defined location per Member and uses shared infrastructure with the National Clearing House. It is available for a Member with low payment instrument volumes and as a back-up for Members using the "Stand Alone Client Module".

- STAND ALONE CLIENT MODULE – This optionrequires Members to have additional infrastructure at its Head Office and allows for multiple locations (branches) to

connect to the National Clearing System. The Share Client Module is required as a back-up system for Members using the "Stand Alone Client Module".

Infrastructure requirements are contained in the "Client Module User Guide" and sample forms for these Set-Up and Acceptance arrangements are provided in the Appendix 12– "Setting Up and Operating the Client Module System".

Each Member will incur additional infrastructural and operational costs outside the scope and responsibility of the National Clearing House as follows:

- Computer Hardware for hosting the National Clearing House "Client Module" software
- Internet connectivity with the National Clearing House Website.

### 1.4 Appointment of the National Clearing House as Settlement Agent

This is an official agreement between the National Clearing House and each Member. On behalf of each Member, the Settlement Agent plays a role in preparing and accepting input file, send output file to Members, and advising binding multilateral net settlement obligation for each Member to NBC Account Management Division hereby referred to as "Account Management Division" for posting of settlement entries automatically. The appointment and authorization of agent is the Members' obligation to be implemented by entering a separate agreement on "Appointment of the National Clearing House as Settlement Agent" between the National Clearing House and each Member. This agreement is attached as Appendix 3– "Appointment of the National Clearing House as Settlement Agent".

### 1.5 National Clearing House Service Level Agreement

This is a binding agreement which sets performance targets to be achieved. The Service Level Agreement provides a framework for measuring performance as a common management tool for all parties. This agreement is attached as Appendix 4– "Service Level Agreement".

### 1.6 National Clearing House Services

The National Clearing House will provide the Clearing and Settlement services, consisted of National Clearing System and FAST Real Time Remittance System (FAST System), to Members and advice of settlement obligations to Account Management Division. . In this role, the National Clearing House shall be a location of exchange, presentation and settlement of non-cash payment instruments (cheques, drafts, credit remittance and similar payment orders etc.) drawn on and payable to Members at par and a location of storing electronic records of such payment instrument. The multilateral net interbank claims shall be settled out of balances on Members settlement accounts maintained separately in KHR and USD.

The National Clearing House will provide full interbank Clearing services for all types of interbank payment instruments and messages (Checks, Returned Checks, Credit Remittances, Direct Credits, Forced Direct Debits and Direct Debit Requests). The exchange of physical Checks and Returned Checks for the Members will be conducted at the National Clearing House or at Check Exchange Centres of the NBC's branch referred to "Check Exchange Centres" which provides secure premises for items exchange and item level reconciliation reports.

The clearing processes will be conducted on the basis of the electronic input received from the input Members and the electronic output prepared by the National

Clearing House for the destination Members. All input and output to/from the National Clearing House will be in electronic form and the payments will be made in the form of batches.

**a. Physical Check Exchanges**

The NBC provides secure premises at National Clearing House and at Check Exchange Centres for the physical check exchange and other physical documentation. A list of current Check Exchange Centres is provided in the Appendix 13- "List of Regional Check Exchange Centres".

**b. Electronic Exchanges**

Electronic and relevant item exchanges including clearing and settlement process of all payment instruments are centralized and conducted at National Clearing House premises provided by the National Bank of Cambodia.

**c. Management of Physical and Electronic Exchanges**

The NBC appoints a Clearing Leader to be responsible for daily operations such as physical check exchange and all centralized electronic payment message at the National Clearing House. The National Bank of Cambodia also appoints a designated leader at each Check Exchange Centre to be responsible for the smooth completion of physical check exchange processes among Members.

**d. Help Desk**

The National Clearing House will provide other technical assistance services concerning with system, operation and related policy inquiries. Member would register emerging issues to the Help Desk or make a call to the National Clearing House via Tel: 023 722 166 / 023 724 866.

**e. Solution to dispute**

